សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal University of Law and Economic

## សារណាបញ្ចប់ការសិក្សា

# អង្គការអយ្យការអមសាលាដំបូង
# រាជធានី-ខេត្ត

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


| | |
|---|---|
| ស្រាវជ្រាវដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **លោក ឈៀង ហុងសេង** | **លោក ជុំ អ៊ីម** |
| **កញ្ញា ណុប ណាវីន** | |


| | |
|---|---|
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា ២០១៨ |
| ជំនាន់ ២២ | ឆ្នាំសរសេររបាយការណ៍ ២០២២ |

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ឈាង ហុងសេង** និងនាងខ្ញុំឈ្មោះ **ណុប ណាទីន** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ក្នុងឆ្នាំសិក្សា២០១៨-២០២២ ជំនាន់ទី២២ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

**លោកឪពុក និងអ្នកម្តាយ** ដែលលោកទាំងពីរបានលះបង់គ្រប់យ៉ាង ទាំងកម្លាំងកាយនិងកម្លាំងចិត្តក្នុងការផ្តល់កំណើតដល់កូនៗដោយក្តីស្រលាញ់ ព្រមទាំងចំណាយពេលវេលាដោយមិនខ្លាចការ នឿយហត់ក្នុងការចិញ្ចឹមបីបាច់ មើលថែរក្សាកូនៗរហូតដល់ធំពេញវ័យ ផ្គត់ផ្គង់ទាំងការរស់នៅប្រចាំថ្ងៃនឹងការ សិក្សាតាំងពីថ្នាក់បឋមរហូតដល់ថ្នាក់បរិញ្ញាបត្រអោយមានចំណេះដឹង សម្រាប់យកមកប្រើប្រាស់ក្នុងសង្គម នេះដោយគ្មានការត្អូញត្អែរ។ ក្នុងនាមយើងខ្ញុំជាកូនរបស់លោកទាំងពីរពិតជាមានមោទនភាពណាស់ដែល បានកើតមកជាកូនរបស់លោកទាំងទ្វេ ដែលលោកតែងតែជម្រុញទឹកចិត្ត ផ្តល់កម្លាំងចិត្ត និងលើកទឹកចិត្ត ដល់ពួកយើងកន្លងមក។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ថ្នាក់ដឹកនាំនៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងលោកគ្រូ-អ្នកគ្រូ ដែលតែងតែអប់រំបណ្តុះបណ្តាលយ៉ាងយកចិត្តទុកដាក់ចំពោះការសិក្សារបស់ខ្ញុំទាំងពីរនាក់កន្លងមក។

យើងខ្ញុំសូមថ្លៃអំណរគុណចំពោះ **ឯកឧត្តម លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់ឱកាសឱ្យយើងខ្ញុំបានចូលមកសិក្សា ស្រាវជ្រាវនៅក្នុងសាកលវិទ្យាល័យមួយនេះ ដែលធ្វើឱ្យយើងខ្ញុំមានចំណេះជំនាញផ្នែកនីតិសាស្ត្រ ដើម្បីយកទៅបម្រើការងារក្នុងសង្គមជាតិ។ ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅម្តងទៀតចំពោះលោកសាស្ត្រាចារ្យ **ដុំ អ៊ីម** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយណែនាំបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ព្រមទាំងផ្តល់ជាដំបូន្មានល្អៗក្នុងការតាក់តែងសៀវភៅនេះឡើងរួមទាំងការកែលំអរ នៅចំណុចខ្វះខាតលើអត្ថបទសារណាមួយនេះរហូតដល់ចប់ជាស្ថាពរ។

ជាចុងក្រោយយើងខ្ញុំទាំងពីរអ្នក សូមបួងសួងអស់វត្ថុស័ក្តសិទ្ធិទាំងឡាយដែលមានក្នុងលោកនេះ សូមជួយថែរក្សាដល់លោកឪពុក-អ្នកម្តាយ មានសុខភាពល្អ មានអាយុយឺនយូរជាម្លប់ត្រជាក់ដល់កូនចៅ និងលោកគ្រូ-អ្នកគ្រូ ព្រមទាំងសាស្ត្រាចារ្យ មានសុខភាពល្អ មានអាយុយឺនយូរ ជួបប្រទះតែសេចក្តីសុខសេចក្តីចម្រើន ដើម្បីអោយលោកបានបន្តចែករំលែកចំណេះដឹងល្អៗ និងបង្ហាត់បង្រៀនដល់និស្សិតជំនាន់ក្រោយៗទៀត។

ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ និងដឹងគុណយ៉ាងជ្រាលជ្រៅបំផុតពីពួកយើងទាំងពីរ។

# អារម្ភកថា

ក្នុងនាមយើងខ្ញុំជានិស្សិតផ្នែកច្បាប់នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ពិតជាមានសោមនស្សរីករាយយ៉ាងក្រៃលែងដែលមានឱកាសបានចងក្រងសារណាដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្រ្តមួយនេះ។ ក្រោយពីបានសិក្សាអស់រយៈពេល៤ឆ្នាំកន្លងមកនេះ យើងខ្ញុំបានជ្រើសរើសប្រធានបទស្តីអំពី «**អង្គភាពអយ្យការអមសាលាដំបូងរាជធានី-ខេត្ត**» មកតាក់តែងឡើងដោយមានការដឹកនាំយ៉ាងយកចិត្តទុកដាក់ពីសំណាក់**លោកសាស្រ្តាចារ្យ ជុំ អ៊ីម** ហើយសៀវភៅមួយក្បាលនេះ គឺជាសម្មិផលនៃការខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវ និងរៀបចំចងក្រង ដោយផ្អែកលើមូលដ្ឋានគតិយុត្តដែលត្រូវបានដកស្រង់ពីអត្ថបទច្បាប់នានាដែលពាក់ព័ន្ធក្នុងគោលបំណងលើកស្ទួយ និងអភិវឌ្ឍន៍លើវិស័យច្បាប់រួមទាំងចែករំលែកចំណេះដឹងដែលពាក់ព័ន្ធនឹងវិស័យច្បាប់ដល់មិត្តៗ និងប្អូនៗជំនាន់ក្រោយគ្រប់គ្នា។

យើងខ្ញុំសង្ឃឹមថាសារណាដែលយើងខ្ញុំទាំងពីរ បានសរសេរឡើងនេះនឹងក្លាយជាឯកសារមួយដែលអាចរំលែកការស្រាវជ្រាវដល់អ្នកទាំងអស់គ្នាក្នុងការស្រាវជ្រាវអត្ថបទដែលពាក់ព័ន្ធអោយកាន់តែងាយ ស្រួលជាងមុន។ យើងខ្ញុំយល់ថាការសរសេរសារណាមួយនេះ អាចមិនទាន់មានសេចក្តីពេញលេញគ្រប់គ្រាន់នៅឡើយទេហើយក៏មិនទាន់បរិយាយឱ្យបានល្អិតល្អន់គ្រប់ជ្រុងជ្រោយផងដែរ។ ហេតុនេះហើយយើងខ្ញុំសូមអភ័យទោសផងដែរនូវរាល់កំហុសខុសឆ្គងទាំងឡាយដែលកើតមាន និងភាពខ្វះចន្លោះផ្សេងទៀតនៅក្នុងសារណានេះ។ យើងខ្ញុំទាំងពីរសូមស្វាគមន៍នូវរាល់មតិរិះគន់ក្នុងការស្ថាបនាទាំងឡាយពីសំណាក់ប្រិយមិត្តអ្នកអានគ្រប់រូបដើម្បីកែលម្អឲ្យស្នាដៃនេះមានអត្ថន័យ និងខ្លឹមសារត្រឹមត្រូវកាន់តែប្រសើរឡើងបន្ថែមទៀត ។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរសូមជូនពរដល់លោកសាស្រ្តាចារ្យក៏ដូចជាមិត្តនិស្សិត និងប្រិយមិត្តអ្នក អានគ្រប់រូបជួបប្រទះតែសេចក្តីសុខ និងភាពជោគជ័យគ្រប់ភារកិច្ចទាំងឡាយអើយ៕

# មាតិកា

**ទំព័រ**


**១.សេចក្តីផ្តើម** ...... ១

## ជំពូកទី១
## សញ្ញាណទូទៅនៃអង្គការអយ្យការ

**ផ្នែកទី១. អង្គការអយ្យការ** ...... ៤

**កថាភាគទី១. អត្ថន័យនៃអង្គការអយ្យការ** ...... ៤

**កថាភាគទី២. តួនាទីរបស់ព្រះរាជអាជ្ញា** ...... ៤

១. គោលការណ៍ឋានានុក្រមនៃអង្គការអយ្យការ ...... ៥

២. គោលការណ៍អង្គអវិភាគនៃអង្គការអយ្យការ ...... ៦

៣. គោលការណ៍អង្គឯករាជ្យនៃអង្គការអយ្យការ ...... ៦

៤. គោលការណ៍មិនអាចប្តឹងជិតចិត្ត ...... ៧

៥. គោលការណ៏កាលានុវត្តភាពនៃចោទប្រកាន់ ...... ៧

៦. គោលការណ៍នៃការមិនទទួលខុសត្រូវ ...... ៧

**កថាភាគទី៣. មុខងារអង្គការអយ្យការ** ...... ៨

១. សាលក្រមស្ថាពរចំពោះមុខ ...... ៩

២. សាលក្រមកំបាំងមុខ ...... ១១

**កថាភាគទី៤. អំណាចរបស់ព្រះរាជអាជ្ញា** ...... ១២

១. ការស៊ើបអង្កេតក្នុករណីបទល្មើសជាក់ស្តែង ...... ១៣

២. ការស៊ើបអង្កេតបឋម ...... ១៤

**ផ្នែកទី២. រចនាសម្ព័ន្ធនៃអង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត** ...... ១៦

**កថាភាគទី១. គ្រប់គ្រង** ...... ១៧

**កថាភាគទី២. ហិរញ្ញវត្ថុ** ...... ១៧

## ជំពូកទី២
## បណ្ដឹងអាជ្ញា

ផ្នែកទី១. ដំណើរការបណ្ដឹងអាជ្ញា..........១៧
កថាភាគទី១. បណ្ដឹងអាជ្ញា..........១៧
កថាភាគទី២. ចលនាបណ្ដឹងអាជ្ញាដោយអយ្យការ..........១៧
កថាភាគទី៣. ចលនាបណ្ដឹងអាជ្ញាដោយជនរងគ្រោះ..........១៨
ផ្នែកទី២. ការរលត់នៃបណ្ដឹងអាជ្ញា
កថាភាគទី១. មរណភាពនៃជនល្មើស..........១៩
កថាភាគទី២. ការផុតអាជ្ញាយុកាល..........១៩
កថាភាគទី៣. ការលើកលែងទោសជាទូទៅ..........២០
កថាភាគទី៤. និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ..........២០
កថាភាគទី៥. អាជ្ញាអស់ជំនុំ..........២០

## ជំពូកទី៣
## ការអនុវត្តបណ្ដឹងអាជ្ញា

ផ្នែកទី១. ជម្រើសនៃការចោទប្រកាន់..........២១
កថាភាគទី១. ការបើកធ្វើការស៊ើបសួរ..........២២
១.ការបើការស៊ើបសួរក្នុងករណីបទឧក្រិដ្ឋ..........២២
២.ការបើកការស៊ើបសួរក្នុងករណីបទមជ្ឈិម..........២៤
កថាភាគទី២. ការបញ្ជូនទៅជំនុំជម្រះផ្ទាល់..........២៤
កថាភាគទី៣. នីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម..........២៧
ផ្នែកទី២. ការតម្កល់រឿងទុកឥតចាត់ការ..........៣០
កថាភាគទី១. មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ..........៣០
១. ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលមិនមែនជាបទល្មើស..........៣០
២. ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើជាបទល្មើស..........៣២
២.១. មូលហេតុគត្តិយុត្តដែលនាំឱ្យតម្កល់រឿងទុកឥតចាត់ការ..........៣២
២.២. ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ..........៣២

**កថាភាគទី២. នីតិវិធីការតម្កល់រឿងទុកឥតចាត់ការ**..........................................៣៤
**កថាភាគទី៣. ការធ្វើបណ្ដឹងតវ៉ាចំពោះការតម្កល់រឿងទុកឥតចាត់ការរបស់អយ្យការ**..........................................៣៥
១. ការប្ដឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍..........................................៣៥
២. ឋានានុក្រមនៃអង្គការអយ្យការ..........................................៣៥
៣. ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ..........................................៣៥
**កថាភាគទី៤. អនុភាពនៃការតម្កល់រឿងទុកឥតចាត់ការ**..........................................៣៧
១. ការតម្កល់រឿងទុកឥតចាត់ការគ្មានអាជ្ញាអស់ជំនុំទេ..........................................៣៧
២. ការសើរើកែប្រែសេចក្ដីសម្រេចរបស់ព្រះរាជអាជ្ញា..........................................៣៧
**សេចក្ដីសន្និដ្ឋាន**..........................................៣៨
**អនុសាសន៍**..........................................៣៩
**គន្ថនិទេស**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

នៅក្នុងដំណើររឿងក្តីព្រហ្មទណ្ឌ ដោយប្រទេសកម្ពុជាប្រកាន់យកប្រព័ន្ធច្បាប់ស៊ីវិល ដែលមានអង្គការអយ្យការជាអ្នកទទួលបន្ទុកចោទប្រកាន់អំពី បទល្មើសព្រហ្មទណ្ឌ ដែលមានចែងនៅក្នុងក្រមនីតិព្រហ្មទណ្ឌ ដែលចូលជាធរមាន។ អយ្យការ គឺជាស្ថាប័នដែលមានតួនាទីចោទប្រកាន់ដែលមានព្រះរាជអាជ្ញាជាអ្នកសម្រេច។ រដ្ឋអាជ្ញា ឬព្រះរាជអាជ្ញា គឺដូចគ្នាប៉ុន្តែពាក្យថា អាជ្ញា គឺជាអំណាច អាស្រ័យនេះហើយបានជាព្រះរាជអាជ្ញា គឺគេប្រើសម្រាប់ប្រទេសដែលមានស្តេចសោយរាជ្យ តែបើប្រទេសគ្មានស្តេចគេហៅថា រដ្ឋអាជ្ញាតែប៉ុណ្ណោះ។ អយ្យការអមតុលាការ គឺមានន័យថា ស្ថាប័នមួយដែលមិនស្ថិតនៅក្រោមអំណាចរបស់តុលាការទេ តែជាស្ថាប័នចោទប្រកាន់ទៅលើជនណាម្នាក់ដែលប្រព្រឹត្តខុស ឬ ប្រឆាំងនឹងច្បាប់ទាក់ទងរឿងព្រហ្មទណ្ឌ។ យោងក្រមនីតិវិធីព្រហ្មទណ្ឌ ស្តីអំពីតួនាទីអង្គការអយ្យការ បានចែងថាអង្គការអយ្យការ ធ្វើការចោទប្រកាន់ ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់។ អង្គការអយ្យការធានាការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន។ [1] ត្រង់នេះហើយបានជាអយ្យការមានសិទ្ធិអំណាចប្រើប្រាស់កម្លាំងសមត្ថកិច្ចនៅតាមបណ្តាខេត្ត និងរាជធានីរួមមាន៖ នគរបាល កងរាជអាវុធហត្ថ មន្ត្រីមេព្រៃ មន្ត្រីជលផលជាដើម។ យ៉ាងណាមិញ អ្នកដឹកនាំខ្ពស់ជាងគេនៅក្នុងស្ថាប័នអយ្យការ គឺព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង គេមិនហៅថា ជាប្រធានអយ្យការ ឬ ប្រធានព្រះរាជអាជ្ញានោះទេ។ ពិសេសករណីទាក់ទងនឹងរឿងក្តីព្រហ្មទណ្ឌបើនគរបាលយុត្តិធម៌ ឬ កម្លាំងកងរាជអាវុធហត្ថចុះបង្ក្រាបបទល្មើសអ្វីមួយត្រូវតែឆ្លងយោបល់ពីព្រះរាជអាជ្ញា ដែលជាស្ថាប័នអយ្យការជាមុនសិន មានន័យថា គឺមិនអាចរំលងទៅដល់តុលាការបានទេ លើកលែងតែបទល្មើសព្រហ្មទណ្ឌជាក់ស្តែងដែលមន្ត្រីនគរបាលត្រូវចាប់ខ្លួនជនណាម្នាក់ ប៉ុន្តែបន្ទាប់ពីចាប់ជននោះហើយត្រូវតែរាយការណ៍មកព្រះរាជអាជ្ញាជាចាំបាច់ តែបើបទល្មើសមិនជាក់ស្តែងត្រូវរាយការណ៍មកព្រះរាជអាជ្ញាជាមុន។ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមអយ្យការមានសិទ្ធិប្រើប្រាស់កម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ(នគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងភ្នាក់ងារសាធារណៈដ៏ទៃទៀតដែលច្បាប់បានប្រគល់អំណាចឲ្យចៅក្រមអយ្យការ ត្រូវតែមានវត្តមាននៅក្នុងពេលសវនាការរឿងព្រហ្មទណ្ឌ។ ហេតុដែលនាំឲ្យចៅក្រមអយ្យការ ត្រូវតែមានវត្តមាននៅក្នុងសវនាការចំពោះរឿងក្តីព្រហ្មទណ្ឌ ព្រោះអង្គការអយ្យការមានតួនាទីជាអ្នកទទួលបន្ទុកចោទប្រកាន់នៅក្នុងរឿងក្តីព្រហ្មទណ្ឌ តាមរយៈការធ្វើបណ្តឹងអាជ្ញា ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមអយ្យការត្រូវតែមានវត្តមាននៅក្នុងសវនាការរឿងក្តី

[1] មាត្រា ២៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ព្រហ្មទណ្ឌ[2] និងយោងតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិថា មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា។[3]

ដូចចម្ដេចដែលហៅថា ចៅក្រមអយ្យការ?

ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានចែងថាចៅក្រមអយ្យការបែងចែកជា ៣ប្រភេទគឺៈ អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និង ព្រះរាជអាជ្ញា អមតុលាការកំពូល អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង។[4]

អង្គការអយ្យការអមសាលាដំបូង គឺសំដៅទៅលើចៅក្រមអយ្យការ។ ដូចគ្នានេះផងដែរព្រះរាជអាជ្ញាធ្វើចំណាត់ការអ្វីមួយក្នុងនាមជាអ្នកការពារនៃផលប្រយោជន៍សង្គម ឬប្រទេសជាតិទាំងមូល មិនមែនដើម្បីបុគ្គលណាម្នាក់ ឬស្ថាប័នណាមួយទេ។ ដោយឡែកនៅក្នុងការចាត់ការសំណុំរឿង ដែលជារឿងបច្ចេកទេសនោះប្រធានតុលាការ ឬចៅក្រមមិនអាចជ្រៀតជ្រែក ឬបញ្ជាទៅខាងអយ្យការបាននោះទេ។ ចំណែកឯព្រះរាជអាជ្ញាវិញក៏មិនអាចបង្គាប់បញ្ជាឲ្យចៅក្រមធ្វើតាមការយល់ឃើញរបស់ខ្លួនដែរ។ ប្រសិនបើសេចក្ដីសម្រេចរបស់ចៅក្រម ដែលសម្រេចសេចក្ដីនោះធ្វើឲ្យព្រះរាជអាជ្ញាយល់ឃើញថាមិនសមស្របព្រះរាជអាជ្ញាមានសិទ្ធប្ដឹងទៅសាលាឧទ្ធរណ៍បានទៅលើសេចក្ដីសម្រេចនោះ។

ដូចច្នេះសរុបសេចក្ដីដោយយោងតាមការបកស្រាយខាងលើរួមមកនាំឲ្យឃើញថា នៅពេលជំនុំជម្រះក្ដីឬពេលសវនាការ មានវត្តមានមន្ត្រីទាំងពីរស្ថាប័នចូលរួម គឺស្ថាប័នតុលាការ និងស្ថាប័នអយ្យការ ដោយខាងតុលាការគេហៅថាចៅក្រមជំនុំជម្រះ រីឯចំណែកខាងអយ្យការ គេហៅថាតំណាងអយ្យការ។ ហេតុនេះហើយស្ថាប័នទាំងពីរនេះ គឺជាស្ថាប័នដែលមានតំណតភ្ជាប់ប្រាស្រ័យទាក់ទងទៅនឹងដំណើរការនីតិវិធីក្នុងដំណើររឿងក្ដីព្រហ្មទណ្ឌ ទន្ទឹមគ្នានេះដែរ ចៅក្រមអយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសុំឲ្យអនុវត្តច្បាប់ចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ អាស្រ័យហេតុនេះហើយបានជានៅតាមតុលាការគេដាក់ឈ្មោះថា សាលាដំបូង និងអយ្យការអមតុលាការជាដើម៕

---

[2] មាត្រា២៧ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[3] មាត្រា១៣១ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[4] មាត្រា២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

# ជំពូកទី១

# សញ្ញាណទូទៅនៃអគ្គការអយ្យការ

# ជំពូកទី១
# សញ្ញាណទូទៅនៃអង្គការអយ្យការ

## ផ្នែកទី១. អង្គការអយ្យការ

### កថាភាគទី១. អត្ថន័យនៃអង្គការអយ្យការ

អង្គការអយ្យការ ជាអង្គការដែលនៅអមសាលាជំនុំជម្រះក្តីជាន់ទាប ដែលមាននៅអមសាលាដំបូងរាជធានី-ខេត្ត ហៅថាអយ្យការអមសាលាដំបូងរាជធានី-ខេត្ត។ ដូចគ្នានេះដែរ អង្គការអយ្យកា គឺជាស្ថាប័នមួយសម្រាប់រដ្ឋសម្រាប់ដំណើរការបណ្តឹងសាធារណៈ ឬ បណ្តឹងព្រហ្មទណ្ឌ។ អង្គការអយ្យការអមសាលដំបូងរាជធានី-ខេត្ត រួមមាន: ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូង។

អយ្យការ គឺជាស្ថាប័នមួយដែលនៅដាច់ដោយឡែកពីតុលាការថ្វីត្បិតតែស្ថាប័ននេះនៅក្នុងបរិវេណតុលាការក៏ពិតមែនតែស្ថាប័នអយ្យការមានអ្នកដឹកនាំដោយឡែកផ្សេងពីតុលាការ។ ប៉ុន្តែ មន្ត្រីដែលបម្រើការងារនៅក្នុងស្ថាប័នទាំងពីរ នេះសុទ្ធសឹងតែជាអ្នកចេញពីសាលាចៅក្រមដូចគ្នា ដោយគ្រាន់តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បែងចែកឲ្យបំពេញមុខងារផ្សេងៗគ្នា តែប៉ុណ្ណោះ។ ចៅក្រម ដែលត្រូវតែងតាំងឲ្យទៅបំពេញមុខងារនៅខាងស្ថាប័នតុលាការ ខ្លះជាចៅក្រម ខ្លះជាប្រធានតុលាការ និងខ្លះជាអនុប្រធានតុលាការ។ ចំណែក ចៅក្រមដែលត្រូវតែងតាំងឲ្យទៅបំពេញមុខងារនៅស្ថាប័នអយ្យការ ខ្លះជាព្រះរាជអាជ្ញា និងខ្លះជាព្រះរាជអាជ្ញារង។

នៅក្នុងកំឡុងពេលឡើងជំនុំជម្រះក្តី ឬ ហៅថាពេលសវនាការ ដែលមានវត្តមានមន្ត្រីទាំងពីរស្ថាប័ន គឺស្ថាប័នតុលាការ និងស្ថាប័នអយ្យការ ខាងតុលាការគេហៅថា **ចៅក្រមជំនុំជម្រះ** និងខាងអយ្យការ គេហៅថា **តំណាងអយ្យការ** មិនមែនហៅថាព្រះអាជ្ញា ឬ ព្រះរាជអាជ្ញារងនោះទេ។

ព្រះរាជអាជ្ញា គឺជាមន្ត្រីដែលស្ថិតនៅក្នុងស្ថាប័នអយ្យការ ជាអ្នកទទួលបន្ទុកស្វែងរកបទល្មើសព្រហ្មទណ្ឌធ្វើការចោទប្រកាន់ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះក្នុងនាមផលប្រយោជន៍សង្គម។

### កថាភាគទី២. តួនាទីរបស់ព្រះរាជអាជ្ញា

អង្គការអយ្យការ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់។ អង្គការអយ្យការធានារ៉ាប់រងការអនុវត្តសម្រេចខាងបទព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន។ នៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន ចៅក្រមអយ្យការមានសិទ្ធិកេណ្ឌប្រើប្រាស់កម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយ។ ចៅក្រមអយ្យការ ត្រូវតែមានវត្តមាននៅក្នុងពេលសវនាការរឿងព្រហ្មទណ្ឌ។[5]

[5] មាត្រា ២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

នៅក្នុងការអនុវត្តតួនាទីរបស់ខ្លួន អង្គការអយ្យការគោរពគោលលការណ៍ដូចខាងក្រោម៖

**១. គោលការណ៍ឋានានុក្រមនៃអង្គការអយ្យការ**

អង្គការអយ្យកា ជាអង្គឯកភាពដែលព្រះរាជអាជ្ញាទាំងអស់ត្រូវស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យតាមឋានានុក្រមរបស់ខ្លួន។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយឋានានុក្រមនៃអង្គការអយ្យ ហើយអាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចប្ដឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូង អំពីបទល្មើសដែលខ្លួនបានដឹង អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ ដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងឲ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ឬធ្វើសេចក្ដីសន្និដ្ឋានយ៉ាងណាតាមការដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មិនអាចធ្វើអធិបញ្ញាដល់អគ្គព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញា ឲ្យតម្កល់ទុកឥតចាត់ការនូវរឿងក្ដីព្រហ្មទណ្ឌណាមួយបានឡើយ។[6] អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ ជាសេនាធិការឲ្យ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកិច្ចការនេះ។

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អមតុលាការកំពូល គឺជានាយឋានានុក្រមនៃមហាអយ្យការ។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺជានាយឋានានុក្រមនៃមហាអយ្យការអមសាលាឧទ្ធរណ៍។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានអំណាចលើចៅក្រមអយ្យការទាំងអស់ ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ អគ្គព្រះរាជអាជ្ញា អាចធ្វើអធិបញ្ញាឲ្យចោទប្រកាន់ ឬ ក៏ចាត់ឲ្យចោទប្រកាន់ ឬ ធ្វើសេចក្ដីសន្និដ្ឋានយ៉ាងណា ដែលខ្លួនយល់ឃើញថាសមស្រប។

ចៅក្រមអយ្យការ គ្រប់រូបត្រូវគោរពតាមអធិបញ្ញាថ្នាក់លើរបស់ខ្លួនតាមឋានុក្រម ប៉ុន្តែ នៅពេលសវនាការចៅក្រមអយ្យការធ្វើការកត់សំគាល់ផ្ទាល់មាត់ដោយសេរីតាមការ ដែលខ្លួនយល់ឃើញថា ស្របតាមសតិបសម្បជញ្ញៈរបស់ខ្លួន គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះចៅក្រមអយ្យការដោយសារតែវាចាររបស់ខ្លួនដែលបានបញ្ចេញនៅក្នុងពេលសវនាការទេ។[7]

ព្រះរាជអាជ្ញាអមសាលាដំបូង គឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញារងទាំងអស់នៃអយ្យការអមសាលាដំបូង ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។ ព្រះរាជអាជ្ញា អាចធ្វើអធិបញ្ញាឲ្យចៅក្រមអយ្យការ(ព្រះរាជអាជ្ញារង)ធ្វើការ

[6] មាត្រា ២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[7] មាត្រា ៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ចោទប្រកាន់ ចាត់ឲ្យចោទប្រកាន់ ឬ ក៏ធ្វើសេចក្ដីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ។ សេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញារង ត្រូវតែបញ្ជូនទៅព្រះរាជអាជ្ញាពិនិត្យនៅមុនពេលសវនាការ។ ប្រសិនបើព្រះរាជអាជ្ញាមិនយល់ព្រមលើសេចក្ដីសន្និដ្ឋាននោះទេ ហើយតំណាងអយ្យការដែលជាអ្នកធ្វើសេចក្ដីសន្និដ្ឋាននោះនៅតែមិនព្រមធ្វើតាម ព្រះរាជអាជ្ញាអាចចាត់តាំងព្រះរាជអាជ្ញារងផ្សេងទៀត ឬ ចាត់តាំងខ្លួនឯងតែម្ដងឲ្យធ្វើជាតំណាងអយ្យការ នៅក្នុងពេលសវនាការនៃសាលាដំបូង។ ប៉ុន្តែ នៅក្នុងសវនាការព្រះរាជអាជ្ញារង អាចធ្វើការកត់សម្គាល់ ដោយផ្ទាល់មាត់បានដោយសេរីតាមការដែលខ្លួនយល់ឃើញថាស្របតាមសតិសម្បជញ្ញៈរបស់ខ្លួន គ្មានការចោទប្រកាន់ខាងវិន័យណាមួយដែលអាចត្រូវធ្វើចំពោះតំណាងអយ្យការ ដោយសារតែការកត់សម្គាល់ផ្ទាល់មាត់របស់ខ្លួននាពេលសវនាការខុសពីសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរឡើយ។ ក្នុងករណីមានធុរៈ មានជំងឺ ឬ អវត្តមាន ព្រះរាជអាជ្ញាត្រូវចាត់តាំងព្រះរាជអាជ្ញារងដើម្បីជំនួសបាន។ ក្នុងករណីដែលព្រះរាជអាជ្ញាស្ថិតក្នុងស្ថានភាពមិនអាចបំពេញមុខងារបាន ឬ ក្នុងករណីតំណែងព្រះរាជអាជ្ញាស្ថិតនៅក្នុងស្ថានភាពទំនេររដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ឲ្យធ្វើជាព្រះរាជអាជ្ញាស្ដីទីជំនួសព្រះរាជអាជ្ញាជាផ្លូវការបាន ដើម្បីធានាដំណើរការរបស់អយ្យការអមសាលាដំបូង រហូតដល់មានការតែងតាំងព្រះរាជអាជ្ញាថ្មី។

### ២. គោលការណ៍អង្គអវិភាគនៃអង្គការអយ្យការ

អង្គការអយ្យការ គឺជាអង្គអវិភាគដែលតម្រូវឲ្យព្រះរាជអាជ្ញា ត្រូវបំពេញមុខងារនៅអង្គការអយ្យការអមសាលាជម្រះក្ដីណាមួយដែលមានកាតព្វកិច្ចរួមមុខងារដូចគ្នា និងអាចជំនួសគ្នាទៅវិញទៅមកបាន។ តាមគោលការណ៍នេះតំណាងអយ្យការច្រើនរូប អាចបន្តការងារពីគ្នាបាននៅក្នុងសំណុំរឿងតែមួយតាមការចាត់តាំងរបស់នាយឋានានុក្រម។[8]

### ៣. គោលការណ៍អង្គឯករាជ្យនៃអង្គការអយ្យការ

អង្គការអយ្យ គឺជាអង្គឯករាជ្យ ដែលមិនស្ថិតនៅក្រោមអំណាចនៃសាលាជម្រះក្ដីដែលខ្លួននៅអមនោះទេ។ សាលជម្រះក្ដីនេះគ្មានសិទ្ធិអំណាចត្រួតពិនិត្យកិច្ចការរបស់ព្រះរាជអាជ្ញាឡើយ។ ទោះបីក្នុងករណីដែលព្រះរាជអាជ្ញាមានកំហុសឆ្គងក្នុងការបំពេញមុខងារក៏ដោយ ក៏សាលាជម្រះក្ដីមិនត្រូវចុះក្នុងសេចក្ដីសម្រេចរបស់ខ្លួនយកការស្ដីបន្ទោសអ្វីចំពោះព្រះរាជអាជ្ញាឡើយ។ ការហាមឃាត់នេះត្រូវអនុវត្តទាំងក្នុងរឿងក្ដីព្រហ្មទណ្ឌទាំងក្នុងរឿងក្ដីផ្សេងទៀត។ ប៉ុន្តែ សាលាជម្រះក្ដីអាចលើកសំណើរទៅនាយឋានានុក្រមរបស់ព្រះរាជអាជ្ញា អំពីកំហុសឆ្គងរបស់ព្រះរាជអាជ្ញាបាន។[9]

[8] មាត្រា ៧៥ នៃច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាឆ្នាំ២០១៤

[9] មាត្រា ៧៥ នៃច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាឆ្នាំ២០១៤

### ៤. គោលការណ៍មិនអាចប្ដឹងជំទាស់ចិត្ត

ការប្ដឹងដកហូតព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង ក្នុងសំណុំរឿងណាមួយមិនអាចអនុវត្តបានដូចចៅក្រម អសនៈនោះទេ ព្រោះគាត់ជាម្ចាស់នៃបណ្ដឹងអាជ្ញាក្នុងនាមសង្គម យ៉ាងណាមិញ បណ្ដឹងអាជ្ញាត្រូវអនុវត្តក្នុង នាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ។[10] ការប្ដឹងដកហូតព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង ក្នុងសំណុំរឿងគឺ ពុំមានច្បាប់ណាចែងណោះទេ។ អង្គការអយ្យការដែលមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងដែលស្ថិតក្នុង តំណាងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត មិនត្រូវបានពាក់ព័ន្ធទៅនឹងការប្ដឹងជិតចិត្តបានទេ ពីព្រោះព្រះ រាជអាជ្ញាធ្វើការចោទប្រកាន់ក្នុងនាមជាអ្នកតំណាងឲ្យរដ្ឋ ហើយព្រះរាជអាជ្ញាមិនតំណាងឱ្យខ្លួនឯងនោះទេ បើ ទោះបីជាព្រះរាជអាជ្ញាមានការជាប់ពាក់ព័ន្ធនឹងសាច់ញាតិ ឬ មានផលប្រយោជន៍ក្នុងបណ្ដឹងក៏ដោយ។ម្យ៉ាងវិញ ទៀត ទោះបីជាមានការចោទប្រកាន់របស់ព្រះរាជអាជ្ញាក៏ដោយ ក៏មិនមែនបានន័យថាបុគ្គលនោះជាជនដែល បានប្រព្រឹត្តបទល្មើសនោះឡើយ។

### ៥. គោលការណ៍កាលានុវត្តភាពនៃចោទប្រកាន់

ក្រោយពេលដែលព្រះរាជអាជ្ញាទទួលបានសំណុំរឿងពីមន្ត្រីនគរបាលយយុត្តិធម៌ ឬ ទទួលបានបណ្ដឹង បរិហារ ឬ បណ្ដឹងទាមទារដែលខ្លួនទទួលដោយផ្ទាល់។ ព្រះរាជអាជ្ញាដើម្បីថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យ បណ្ដឹង និងពាក្យបរិហាដែលខ្លួនទទួលបានដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក ព្រះរាអាជ្ញា សម្រេចចោទប្រកាន់ ឬ មិនចោទប្រកាន់(តម្កល់រឿងទុកឥតចាត់ការ) មុននឹងសម្រេចព្រះរាជអាជ្ញាបើកការស៊ើប អង្កេតបឋម ឬ បង្គាប់ឲ្យស្រាវជ្រាវបន្ថែម ។ ក្នុងករណីបទល្មើសធ្ងន់ធ្ងរ ព្រះរាជអាជ្ញារាយការណ៍ជូនអគ្គព្រះរាជ អាជ្ញាអមសាលាឧទ្ធរណ៍ ដែលត្រូវរាយការណ៍បន្តជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[11]

### ៦. គោលការណ៍នៃការមិនទទួលខុសត្រូវ

ព្រះរាជអាជ្ញាក្នុងនាមជាអ្នកតំណាងឲ្យរដ្ឋ ក្នុងការចោទប្រកាន់ចំពោះអង្គហេតុទាំងឡាយណាដែលគិត ថាជាបទល្មើសព្រហ្មទណ្ឌ។ ក្នុងករណីខ្លះ អង្គហេតុដែលព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់អាចនឹងត្រូវច្រាន ចោលដោយចៅក្រមស៊ើបសួរ នៅក្នុងដំណាក់កាលនៃការស៊ើបសួរ ឬ ដោយចៅក្រមជំនុំជម្រះ ប្រសិនបើអង្គ ហេតុនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌ ឬ មិនមានភស្តុតាងក្នុងការដាក់បន្ទុកគ្រប់គ្រាន់ដើម្បីកំណត់ធាតុផ្សំ នៃបទល្មើស។ ប្រសិនបើមានករណីនេះកើតមានឡើង ព្រះរាជអាជ្ញាមិនអាចត្រូវទទួលខុសត្រូវរាល់ការខូតខាត ទាំងឡាយដែលកើតចេញពីការសម្រេចចិត្តរបស់ព្រះរាជអាជ្ញាទៅលើរឿងក្ដីដែលខ្លួនទទួលខុសត្រូវ ជាពិសេស ជនត្រូវចោទ ឬ ជនជាប់ចោទនៅក្នុងសំណុំរឿងនោះទេ។ ផ្ទុយមកវិញ គោលការណ៍នៃការមិនទទួលខុសត្រូវ នៃ

[10] មាត្រា ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[11] មាត្រា ៤០ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

អង្គការអយ្យការនៅក្នុងការចោទប្រកាន់មិនមែនបានន័យថា ព្រះរាជអាជ្ញាអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ នៅពេលដែលខ្លួនបានប្រព្រឹត្តកំហុសជាបទល្មើសព្រហ្មទណ្ឌ ដោយកើតចេញពីឆន្ទៈទុច្ចរិតនៅពេលបំពេញការងាររបស់ខ្លួននោះទេ។ ហេតុនេះ ប្រសិនបើមានករណី ដែលព្រះរាជអាជ្ញាបានប្រព្រឹត្តកំហុសដែលជាបទល្មើសព្រហ្មទណ្ឌណាមួយនោះ នាំឱ្យព្រះរាជអាជ្ញាត្រូវតែទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌដែលខ្លួនបានប្រព្រឹត្ត។

**កថាភាគទី៣. មុខងារអង្គការអយ្យការ**

ការតំណាងអង្គការអយ្យការអមសាលាដំបូង ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូងជាតំណាងអង្គការអយ្យការអមតុលាការនេះ។

នៅក្នុងរឿងព្រហ្មទណ្ឌ យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានចែងថា "មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា" ។[12]

យោងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជម្រះក្តីចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៣ បានចែងថាក្នុងរឿងព្រហ្មទណ្ឌក្រុមអយ្យការជាម្ចាស់នៃបណ្តឹងអាជ្ញា និងធ្វើការសន្និដ្ឋានទោសដោយតាំងខ្លួនជាគូក្តីដើមជាដរាប។[13]

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងបន្ថែមទៀតថា បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ដោយអយ្យការ អយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។[14] មានន័យថាព្រះរាជអាជ្ញាជាម្ចាស់បណ្តឹងអាជ្ញា និងជាគូក្តីដើមក្នុងរឿងព្រហ្មទណ្ឌដើម្បីការពារ រក្សាសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម តាមរយៈការចោទប្រកាន់ប្រឆាំងនឹងបុគ្គលទាំងឡាយណាដែលបានរំលោភច្បាប់។

យោងតាមច្បាប់រៀបចំអង្គការតុលាការ ព្រះរាជអាជ្ញាត្រូវតែមានវត្តមាននៅគ្រប់សវនាការទាំងអស់នៃរឿងក្តីព្រហ្មទណ្ឌ និងរឿងក្តីផ្សេងទៀតដែលច្បាប់កំណត់[15] និងផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានចែងបញ្ជាក់ថាក្នុងរឿងក្តីព្រហ្មទណ្ឌនេះព្រះរាជអាជ្ញាជាអ្នកប្តឹងទៅតុលាការ ហើយត្រូវតែបង្ហាញឲ្យបានច្បាស់នូវអ្វីដែលខ្លួនបានចោទប្រកាន់។ ក្នុងពេលជំនុំជម្រះតំណាងអយ្យការត្រូវចូលរួមជាចំបាច់ បើពុំដូច្នោះទេ តុលាការមិនអាចធ្វើការជំនុំជម្រះ ឬកាត់ទោសជនល្មើសបានឡើយ ។ ព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ខាងព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យមានការអនុវត្តន៍ច្បាប់ ហើយព្រះរាជអាជ្ញា ក៏ធានារ៉ាប់រងការអនុវត្តន៍

---

[12] មាត្រា ១៣១ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[13] មាត្រា ៥ កថាខណ្ឌ២ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជម្រះក្តីឆ្នាំ១៩៩៣

[14] មាត្រា៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[15] មាត្រា ៨ កថាខណ្ឌ ៤ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការឆ្នាំ២០១៤

សេចក្តីសម្រេចខាងព្រហ្មទណ្ឌ និងសិទ្ធិធ្វើបណ្តឹងអាជ្ញា សិទ្ធិអំណាចធ្វើការស៊ើបអង្កេតបឋមក្នុងករណីកើតមានបទល្មើសឧក្រិដ្ឋ ឬបទល្មើសមជ្ឈិមជាក់ស្តែង អំណាចធ្វើការចាប់ខ្លួន ការឃាត់ខ្លួន ចោទប្រកាន់ និងសិទ្ធិអំណាចច្រើនទៀតដែលច្បាប់បានផ្តល់ឲ្យ។

**១. សាលក្រមស្ថាពរចំពោះមុខ**

សាលក្រមចូលជាស្ថាពរ គឺមានន័យថាផុតរយៈពេលប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ហើយ គឺមិនអាចធ្វើការកែប្រែបានឡើយ សូម្បីតែព្រះរាជអាជ្ញា ហើយតុលាការសាមីដែលចេញសាលក្រមនោះក៏មិនអាចកែប្រែសេចក្តីសម្រេចរបស់ខ្លួនបានផងដែរ។

ចំពោះសាលក្រមព្រហ្មទណ្ឌ ដែលចូលជាស្ថាពរហើយតម្រូវឱ្យមានការដាក់ទោសជនសង្ស័យ ឬជនត្រូវចោទទោះបីមិនមានការស្នើសុំពីភាគីដើមបណ្តឹង ក៏ព្រះរាជអាជ្ញាត្រូវអនុវត្តភ្លាមដែរព្រោះគាត់ជាដើមបណ្តឹងអាជ្ញា។ ការចុះអនុវត្តសាលក្រមនេះ ត្រូចបែងចែកជាពីរផ្នែក គឺៈ

សាលក្រមចំពោះមុខ ឬសាលដីកា គឺជាសាលក្រម ឬសាលដីកា ដែលសម្រេចសេចក្តីក្នុងករណីដែលជនជាប់ចោទចូលបង្ហាញខ្លួនក្នុងពេលសវនាការ។ សាលក្រម ឬសាលដីកានៅតែចំពោះមុខដដែល បើទោះបីជនជាប់ចោទចាកចេញពីបន្ទប់សវនាការភ្លាមៗក៏ដោយ។ សាលក្រម ឬសាលដីកាអាចជាចំពោះមុខផងដែរកាលណាជនជាប់ចោទត្រូវបានសួរចម្លើយនៅទីកន្លែងដែលជននោះនៅ។

សាលក្រមចំពោះមុខ ឬសាលដីកាចំពោះមុខ ស្របតាមលក្ខខណ្ឌនៃក្រមនីតិវិធីព្រហ្មទណ្ឌដែលនៅជាធរមាន។

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ប្រសិនបើមូលហេតុស្ថានភាពសុខភាព ឬដោយមូលហេតុធ្ងន់ធ្ងរដែលធ្វើឲ្យជនជាប់ចោទ មិនអាចចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការបានទេ ប្រធានសវនាការអាចបង្គាប់ឲ្យសួរជនជាប់ចោទ នៅទីកន្លែងដែលជននោះនៅ។ តុលាការកំណត់កាលបរិច្ឆេទសួរចម្លើយ ការសួរចម្លើយត្រូវធ្វើដោយប្រធានសវនាការ នៅចំពោះមុខព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមេធាវីជនជាប់ចោទ លើកលែងតែជនជាប់ចោទបោះ(បង់)ចោលយ៉ាងជាក់លាក់នូវវត្តមានមេធាវីរបស់ខ្លួន ការសួរចម្លើយនេះត្រូវតែមានធ្វើកំណត់ហេតុ។[16] ចំពោះដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដែលបានចូលបង្ហាញខ្លួននៅពេលសវនាការ ឬមានអ្នកតំណាងដោយត្រឹមត្រូវនោះសាលក្រម ឬ សាលដីកា ត្រូវតែជាសាលក្រម ឬសាលដីកាចំពោះមុខ។ សាលក្រម ឬ សាលដីកាចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងមុខជនជាប់ចោទនេះ

[16] មាត្រា ៣០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

មិនតម្រូវឲ្យមានការបញ្ជូនឡើយ (មិនចាំបាច់ជូនដំណឹងដល់សាមីជនទាំងនោះទៀតឡើយ)។ សាលក្រម ឬ សាលដីកាចំពោះមុខអាច ប្តឹងឧទ្ធរណ៍ និងប្តឹងសាទុក្ខបាន។

សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ ប្រសិនបើជនជាប់ចោទមិនចូលមកបង្ហាញខ្លួននៅពេលសវនាការ ប៉ុន្តែសាមីខ្លួនបានដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ បានដឹងពីការកោះហៅហើយនោះសាលក្រមត្រូវចាត់ទុកថាជាសាលក្រមចំពោះមុខជនជាប់ចោទ។ សាលក្រមដែលចាត់ទុកថាចំពោះមុខនេះ ត្រូវឲ្យដំណឹងដល់ជនជាប់ចោទ សាលក្រមនេះអាចត្រូវប្តឹងឧទ្ធរណ៍បាន។ ក្នុងករណីដែលជនជាប់ចោទអវត្តមានបានបង្ហាញមូលហេតុអំពីការអវត្តមានរបស់ខ្លួន ហើយតុលាការក៏បានទទួលថាត្រឹមត្រូវនោះ តុលាការអាចលើករឿងទៅជំនុំជម្រះនៅសវនាការមួយក្រោយទៀត។[17] មានន័យថា សាលក្រម ឬសាលដីកាដែលចាត់ទុកថា ចំពោះមុខ គឺជាសាលក្រម ឬសាលដីកាដែលសម្រេចសេចក្តី ក្នុងករណីដែល នៅពេលសវនាការជនជាប់ចោទមិនបានចូលមកបង្ហាញខ្លួននៅពេលនោះទេ ប៉ុន្តែសាមីខ្លួនបានដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ បានដឹងពីការកោះហៅហើយនោះ សាលក្រម ឬ សាលដីកា ត្រូវចាត់ទុកថាចំពោះមុខជនជាប់ចោទ។ សាលក្រម ឬ សាលដីកា អាចចាត់ទុកថាចំពោះមុខនេះ ត្រូវឲ្យដំណឹងដល់ជនជាប់ចោទ ហើយអាចប្តឹងឧទ្ធរណ៍ និងប្តឹងសាទុក្ខបាន។

ព្រះរាជអាជ្ញា ជាអ្នកអនុវត្តសាលក្រម ដោយក្នុងករណីចាំបាច់ព្រះរាជអាជ្ញា អាចប្រើប្រាស់កម្លាំងសាធារណៈបាន បើសាលក្រមស្ថាពរសម្រេចត្រូវផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារ ដូច្នេះ ព្រះរាជអាជ្ញាចេញដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទដាក់ពន្ធនាគារតាមអំណាចរបស់សាលក្រម ។

***ករណីសាលក្រមមិនទាន់ចូលជាស្ថាពរ ភាគីអាចៈ***

-**ប្តឹងឧទ្ធរណ៍ចំពោះសាលក្រមចំពោះមុខ** មានន័យថា គឺជាការធ្វើបណ្តឹងឧបាស្រ័យទៅនឹងសាលក្រមចំពោះមុខទៅសាលាឧទ្ធរណ៍ ដែលមានវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនជាប់ចោទ អ្នកតំណាង នាពេលប្រកាសសាលក្រម។ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ពិរុទ្ធជនអាចធ្វើបណ្តឹងឧទ្ធរណ៍នៅការិយាល័យក្រឡាបញ្ជី នៃសាលាជម្រះក្តីជាន់ទាបតុលាការព្រហ្មទណ្ឌ នៃសាលាដំបូងរាជធានី-ខេត្ត ដែលបានប្រកាសសាលក្រមចំពោះមុខនោះ ដែលទទួលបន្ទុកសំណុំរឿងក្នុងរយៈពេល ០១ (មួយ) ខែ ផ្តើមគិតពីថ្ងៃប្រកាសសាលក្រម។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ រយៈពេលប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញា ព្រះរាជអាជ្ញាធ្វើបណ្តឹងឧទ្ធរណ៍ ក្នុងរយៈពេល ០១ (មួយ) ខែ និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ អាចធ្វើបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល ០៣ (បី)ខែ គិតពីថ្ងៃប្រកាស

[17] មាត្រា ៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

សាលក្រម ឬគិតពីថ្ងៃទទួលបានការជូនដំណឹងក្នុងករណីសាលដីកាចាត់ទុកថាចំពោះមុខ។[18]

**២. សាលក្រមកំបាំងមុខ**

សាលក្រមកំបាំងមុខ ឬសាលដីកាកំបាំងមុខ គឺជាសាលក្រម ឬសាលដីកាសម្រេចសេចក្តីមួយនៅពេលសវនាការ ប្រសិនបើជនជាប់ចោទមិនចូលមកបង្ហាញខ្លួននៅពេលនោះទេ ហើយប្រសិនបើគ្មានភ័ស្តុតាងបង្ហាញឲ្យឃើញថា សាមីខ្លួនដឹងពីដីកាបញ្ជូនខ្លួនទៅជំនុំជម្រះ ឬបានដឹងអំពីការកោះហៅនោះទេ។ ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ ហើយប្រសិនបើគ្មានភស្តុតាងបង្ហាញឲ្យឃើញថាសាមីខ្លួនដឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬ បានដឹងអំពីការកោះហៅនោះទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ។ សាលក្រមកំបាំងមុខជនជាប់ចោទ ត្រូវឲ្យដំណឹងដល់ជនជាប់ចោទនេះ។ សាលក្រមនេះអាចត្រូវប្តឹងទាស់បាន។[19] ម្យ៉ាងវិញទៀត ចំពោះបុគ្គលកោះហៅក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ឬជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី មិនចូលបង្ហាញខ្លួននៅពេលសវនាការ និងគ្មានអ្នកតំណាងត្រឹមត្រូវទេ សាលក្រម ឬសាលដីកាត្រូវសម្រេចដោយកំបាំងមុខដូចគ្នាទៅនឹងជនជាប់ចោទដែរ។ សាលក្រម ឬសាលដីកាកំបាំងមុខនេះ ត្រូវឲ្យដំណឹងដល់សាមីជនទាំងនោះ ហើយសាលក្រម ឬសាលដីកានេះអាចប្តឹងទាស់បាន។

សាលក្រមកំបាំមុខក៏ជាអំណាចរបស់ព្រះរាជអាជ្ញាផងដែរ ក្នុងការអនុវត្តន៍សាលក្រមនេះ ហើយការអនុវត្តន៍សាលក្រមនេះវាមានលក្ខណៈស្រដៀងគ្នាទៅនឹងការអនុវត្តន៍សាលក្រមចំពោះមុខដែរ។ បន្ទាប់ពីទទួលសម្រង់សាលក្រមព្រហ្មទណ្ឌរួចមក ក្រឡាបញ្ជីត្រូវចុះហត្ថលេខាទទួលយកសម្រង់សាលក្រមនេះ ប្រសិនបើត្រូវផ្តន្ទាទោសឲ្យដាក់ពន្ធនាគារ នោះជាមួយសម្រង់សាលក្រមរបស់ចៅក្រមជំនុំជម្រះមកដាក់ពន្ធនាគារតាមសាលក្រម ហើយបញ្ជូនទៅស្នងការដ្ឋាននគរបាលគ្រប់ទីកន្លែងទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីស្វែងរកចាប់ខ្លួនជនល្មើស។

***ករណីសាលក្រមមិនទាន់ចូលជាស្ថាពរ ភាគីអាចះ***

ចំពោះសាលក្រមកំបាំងមុខនេះគេអាចប្តឹងតាមវិធី ២ យ៉ាងគឺ ទី១.ប្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ និងទី២.ប្តឹងឧទ្ធរណ៍ចំពោះសាលក្រមកំបាំងមុខ ពិរុទ្ធជនមិនចាំបាច់ប្តឹងទាស់ក៏បានដែរ គឺគាត់អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមកំបាំងមុខនោះទៅកាន់សាលាឧទ្ធរណ៍តែម្តង ឬ ទៅតុលាការថ្នាក់លើផ្សេងទៀតដើម្បីសុំឱ្យធ្វើការសើរើ ឬជំនុំជម្រះរឿងក្តីរបស់គាត់ឡើងវិញ។

---

[18] មាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[19] មាត្រា៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

**-ប្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ** គឺមានន័យថាតាមនីតិវិធីប្តឹងទាស់នោះ នៅពេលដែលតុលាការថ្នាក់(រាជធានី)ក្រុង ឬ ខេត្តមួយណា ឬ ចៅក្រមមួយណាដែលបានប្រកាសសាលក្រមកំបាំងមុខ ហើយនោះពិរុទ្ធជនអាចធ្វើបណ្តឹងទាស់នឹងសាលក្រមកំបាំងមុខនោះបាន និងស្នើសុំឲ្យតុលាការ ឬ ចៅក្រមនោះធ្វើការកាត់ក្តីលើសំណុំរឿងរបស់គាត់ឡើងវិញ ដោយសារតែគាត់អវត្តមាននៅពេលជំនុំជម្រះ និងនៅពេលសាកសួរដេញដោល។ ដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬ ពិរុទ្ធជន អាចធ្វើបណ្តឹងទាស់នៅការិយាល័យក្រឡាបញ្ជីនៃសាលាជម្រះក្តីជាន់ទាប (តុលាព្រហ្មទណ្ឌនៃសាលាដំបូងរាជធានី-ខេត្ត) ដែលបានប្រកាសសាលក្រមកំបាំងមុខនោះ ដែលទទួលបន្ទុកសំណុំរឿងនោះ ក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ ផ្តើមគិតពីថ្ងៃទទួលបានការជូនដំណឹងអំពីសាលក្រមកំបាំងមុខ ឬ ពីថ្ងៃដែលបានដឹងយ៉ាងពិតប្រាកដ អំពីសាលក្រមកំបាំងមុខនេះ។

**-ប្តឹងឧទ្ធរណ៍ចំពោះសាលក្រមកំបាំងមុខ** គឺមានន័យថា ពិរុទ្ធជនមិនចាំបាច់ប្តឹងទាស់ក៏បានដែរ គឺគាត់អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមកំបាំងមុខនោះទៅកាន់សាលាឧទ្ធរណ៍តែម្តង។

ចំពោះ ប្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ប្តឹងឧទ្ធរណ៍ចំពោះសាលក្រមកំបាំងមុខ អ្នកមានសិទ្ធិធ្វើគឺពិរុទ្ធជន អ្នកតំណាងដោយច្បាប់កំណត់ អ្នកតំណាងដោយអាណត្តិ ឬអ្នកតំណាងពិសេស។

### កថាភាគទី៤. អំណាចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ប៉ុន្តែ កាលណាអនុវត្តដីកាសម្រេចចាត់ឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ។

ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ អំណាចរបស់ព្រះរាជអាជ្ញារួមមានដូចខាងក្រោម៖

- ព្រះរាជអាជ្ញាប្រើប្រាស់អំណាចទាំងអស់ ដែលក្រមនេះទទួលស្គាល់ឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត
- ព្រះរាជអាជ្ញាអាចចុះទៅកន្លែងស៊ើបអង្កេត និងធ្វើគ្រប់ការណែនាំដែលមានប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌
- ក្នុងករណីពិសេស ព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបជំនួសមន្ត្រី និងភ្នាក់ងារនេះ។
- ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលា នៅអង្គភាពនគរបាលយុត្តិធម៌
- ព្រះរាជអាជ្ញាអាចចូលរួមក្នុងការស្តាប់ចម្លើយ អាចត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេសគឺការគោរពទម្រង់ច្បាប់ និងការកាន់កាប់កន្លែងឃាត់ខ្លួន។

- អំណាចរបស់ព្រះរាជអាជ្ញារង ដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ដែលព្រះរាជអាជ្ញាមាន ក្នុងការស្រាវជ្រាវ និងការចោទប្រកាន់បទល្មើស។[20]

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ សមត្ថកិច្ចតាមដែនដីរបស់ព្រះរាជអាជ្ញាមានដូចតទៅ៖

- ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តបទល្មើស។[21]

### ១. ការស៊ើបអង្កេតក្នុងករណីបទល្មើសជាក់ស្តែង

និយមន័យ បទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងគឺ៖ បទល្មើសដែលកំពុងប្រព្រឹត្ត បទល្មើសដែលទើបប្រព្រឹត្តរួច។[22]

ត្រូវចាត់ទុកថាជា បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសចប់បន្តិចមក៖

- ជនដែលគេសង្ស័យ ត្រូវបានសាធារណៈជនស្រែកដេញប្រជាប់ចាប់ប្រកីង
- បុគ្គលដែលគេត្រូវរកឃើញមានវត្ថុ ឬ មានស្លាកស្នាម ឬ តម្រុយច្បាស់លាស់ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឲ្យគេសន្និដ្ឋានបានថាបុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស។

ក្នុងករណីបទល្មើស ឧក្រិដ្ឋជាក់ស្តែង ឬបទមជ្ឈិមជាក់ស្តែងមន្ត្រីនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា។[23] ថេរវេលានៃការស៊ើបអង្កេតបទល្មើសជាក់ស្តែងមិនអាចលើសពី ៧ (ប្រាំពីរ) ថ្ងៃ គិតពីថ្ងៃប្រព្រឹត្តបទល្មើស។ កិច្ចស៊ើបអង្កេតត្រូវប្រព្រឹត្តទៅជាប់ជានិច្ចនៅក្នុងថេរវេលានេះ។ ប្រសិនបើការស៊ើបអង្កេតមិនបានបញ្ចប់ក្នុងរយៈពេល ៧ (ប្រាំពីរ)ថ្ងៃនោះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្នើសុំយោបល់ពីព្រះរាជអាជ្ញា។[24] បុគ្គលទាំងឡាយដែលមានសមត្ថកិច្ចស៊ើបអង្កេតរួមមានៈ មន្ត្រីនគរបាលយុត្តិធម៌ ចៅក្រមខាងអយ្យការក្រឡាបញ្ជី និងក្រុមកងរាជអាវុធហត្ថ។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើការឆែកឆេរបាន ក្នុងករណីទទួលជាបឋមនូវការអនុញ្ញាតពីព្រះរាជអាជ្ញាទោះបីជាការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ។[25]

---

[20] មាត្រា៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។

[21] មាត្រា៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។

[22] មាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[23] មាត្រា ៨៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[24] មាត្រា ១០៦ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[25] មាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

**ការប្រព្រឹត្តទៅនៃការការឆែកឆេរក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្តែងមានដូចតទៅះ**

- ការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ដោយទទួលការអនុញ្ញាតពីអ្នកកាន់កាប់ទីកន្លែង នោះ
- ប្រសិនបើគ្មានអ្នកកាន់កាប់ទីកន្លែងទេ ត្រូវធ្វើនៅបំពោះមុខសាក្សីពីរអ្នក ដែលត្រូវបានចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ សាក្សីមិនអាចជាមន្ត្រីនគរបាលយុត្តិធម៌ ឬ ជាកងរាជអាវុធហត្ថឡើយ ឬ កងកម្លាំងចូលរួមប្រត្តិបត្តការក្នុងការឆែកឆេរនោះទេ
- មន្ត្រីនគរបាលយុត្តិធម៌អាចហៅ និងនាំមកកាន់អង្គភាពរបស់ខ្លួនគ្រប់បុគ្គលដែលពាក់ព័ន្ធសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ដោយធ្វើកំណត់ហេតុទៅលើការស្តាប់ចម្លើយ
- មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលអាចផ្តល់ពត៌មានស្តីអំពីហេតុបានក្នុងការស្តាប់ចម្លើយ

### ២. ការស៊ើបអង្កេតបឋម

ការស៊ើបអង្កេតបឋម មន្ត្រីនគរបាលយុត្តិធម៌បើកតាមការសុំរបស់ព្រះរាជអាជ្ញា តាមរយៈដីការ។ កាលណាបានដឹងពីអំពើដែលអាចជាបទឧក្រិដ្ឋ ឬ បទមជ្ឈឹម ឬ បទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចបើកការស៊ើបអង្កេតបឋមបានដោយឯកឯង ឬតាមការសុំរបស់ព្រះរាជអាជ្ញា។[26]

**ការប្រព្រឹត្តទៅនៃការការឆែកឆេរក្នុងករណីស៊ើបអង្កេតបឋមមានដូចតទៅ ៖**

ការស៊ើបអង្កេតបឋមដែលទាក់ទងទៅ និងបទឧក្រិដ្ឋ ឬបទមជ្ឈឹម មន្ត្រីនគរបាលយុត្តិធម៌ធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង។[27]

- ការឆែកឆេរមិនអាចចាប់ផ្តើមមុនម៉ោង ៦ព្រឹក និងក្រោយម៉ោង៦ល្ងាចឡើយ ការចាប់ផ្តើមធ្វើការឆែកឆេរចាប់ពីម៉ោង ៦ (ប្រាំមួយ) ព្រឹក រហូតដលម៉ោង១៨ (ដប់ប្រាំបី) ល្ងាច
- ការធ្វើការឆែកឆេរ ត្រូវតែដឹកនាំដោយផ្ទាល់ពីព្រះរាជអាជ្ញា ទៅកាន់ទីកន្លែងឆែកឆេរនោះ
- ទទួលបានការយល់ព្រមពីអ្នកកាន់កាប់ទីកន្លែង ដើម្បីធ្វើការឆែកឆេរបានត្រូវឲ្យអ្នកកាន់កាប់ទីកន្លែងសរសេរអក្សរដែលលាយលក្សណ៍ជាអក្សរដោយផ្ទាល់ដៃពីអ្នកកាន់កាប់ទីកន្លែង
- ប្រសិនបើអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរ នោះត្រូវសរសេរឲ្យបានច្បាស់លាស់ក្នុងកំណត់ហេតុថាអ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរ ហើយយល់ព្រមឲ្យឆែកឆេរ

[26] មាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[27] មាត្រា ១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

- ក្នុងករណីអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដី អាចចេញដីកាអនុញ្ញាតឲ្យឆែកឆេរ តាមការសុំរបស់ព្រះរាជអាជ្ញា
- ការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទីកន្លែងទេត្រូវធ្វើនៅចំពោះមុខសាក្សីពីរអ្នក ដែលចាត់តាំងដោយព្រះរាជអាជ្ញា សាក្សីមិនអាចជានគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រត្តិបត្តិក្នុងការឆែកឆេរនោះឡើយ។

## ផ្នែកទី២. រចនាសម្ព័ន្ធនៃអង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

**សមាសភាពអយ្យការអមសាលាដំបូងរាជធានី-ខេត្ត**




ព្រះរាជអាជ្ញាអមសាលាដំបូង មានឋានន្តរសក្តិជាវរៈព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញារង អមសាលាដំបូងទាំងអស់មានឋានន្តរសក្តិជាវរៈព្រះរាជអាជ្ញា ឬអនុព្រះរាជអាជ្ញាឡើងទៅ។ នៅអមសាលាដំបូងរាជធានីខេត្តត្រូវមានអង្គការអយ្យការមួយហៅថា **អយ្យការអមសាលាដំបូង**។

អយ្យការអមសាលាដំបូង ត្រូវដឹកនាំដោយព្រះរាជអាជ្ញា ១រូប និងអមដោយព្រះរាជអាជ្ញារងមួយចំនួនតាមការចាំបាច់។ ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអយ្យការអមសាលាដំបូង ជាតំណាងអយ្យការអមសាលាដំបូងដែលខ្លួនបំពេញការងារ។

សមាសភាពអយ្យការអមសាលាដំបូងមាន៖

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត ដែលបម្រើការងារនៅអយ្យការអមសាលាដំបូង។

**កថាភាគទី១. ការគ្រប់គ្រង**

ចៅក្រមអយ្យការគ្រប់រូប ត្រូវគោរពតាមអធិបញ្ញាថ្នាក់លើរបស់ខ្លួនតាមឋានានុក្រមដែលរួមមាន ៖

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយឋានានុក្រមនៃអង្គការអយ្យការ ហើយអាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់។
- អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ ជាសេនាធិការឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកិច្ចការនេះ។
- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺជានាយឋានានុក្រមនៃមហាអយ្យការអមតុលាការកំពូល។
- ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូលត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺជានាយឋានានុក្រមនៃមហាអយ្យការអមសាលាឧទ្ធរណ៍។
- ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញា ដែលជានាយឋានានុក្រមរបស់ខ្លួន។
- ព្រះរាជអាជ្ញាអមសាលាដំបូង គឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញាទាំងអស់នៃអយ្យការអមសាលាដំបូង ត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។

**កថាភាគទី២. ហិរញ្ញវត្ថុ**

សាលាដំបូង និងអយ្យការអមសាលាដំបូង សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ព្រមទាំងតុលាការកំពូល និងមហាអយ្យការតុលាការកំពូល មានកញ្ចប់ថវិកាដោយឡែកសម្រាប់ដំណើរការដែលស្ថិតនៅក្នុងកញ្ចប់ថវិការបស់ក្រសួងយុត្តិធម៌។

ប្រធានសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ជាអាណាប័កទទួលសិទ្ធិពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ការគ្រប់គ្រង និងការចាត់ចែងថវិការបស់សាលាជម្រះក្តី និងអយ្យការអមសាលាជម្រះក្តីត្រូវកំណត់ដោយអនុក្រឹត្យ។

# ជំពូកទី២
# បណ្តឹងអាជ្ញា

# ជំពូកទី២
# បណ្តឹងអាជ្ញា

## ផ្នែកទី១. ដំណើរការបណ្តឹងអាជ្ញា

### កថាភាគទី១. បណ្តឹងអាជ្ញា

បណ្តឹងអាជ្ញាត្រូវអនុវត្តលើបុគ្គលគ្រប់រូប ទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។[28] យោងតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិថា **មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។**[29] មានន័យថា ការធ្វើបណ្តឹងអាជ្ញា គឺជាសិទ្ធិផ្តាច់មុខរបស់ ស្ថាប័នអយ្យការ ហើយបណ្តឹងអាជ្ញានឹងត្រូវចាប់ផ្តើមដំណើរការ ដោយការចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយដោយអយ្យការ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។

ដូច្នេះ ការធ្វើបណ្តឹងអាជ្ញា គឺជាសិទ្ធិផ្តាច់មុខរបស់ស្ថាប័នអយ្យការ ហើយបណ្តឹងអាជ្ញានឹងត្រូវចាប់ផ្តើមដំណើរការដោយការចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយដោយអយ្យការ ដូចគ្នានេះដែរ បណ្តឹងអាជ្ញាមានអានុភាព នៅពេលដែលព្រះរាជអាជ្ញាធ្វើចំណាត់ការលើបណ្តឹងនោះ។

*បណ្តឹងអាជ្ញាមានគោលបំណង ៖*

- ពិនិត្យអត្ថិភាពនៃបទល្មើស
- បង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនល្មើស
- និងផ្តន្ទាទោសជនដែលបាន ប្រព្រឹត្តិបទល្មើសតាមកំណត់ច្បាប់។[30]

### កថាភាគទី២. ដំណើរបណ្តឹងអាជ្ញាដោយអយ្យការ

បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ។ អយ្យការធ្វើការចោទប្រកាន់អំពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់។ អង្គការអយ្យការ ធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់ លើការផ្សព្វផ្សាយដីការបង្គាប់ឲ្យចាប់ខ្លួន។ ចៅក្រមអយ្យការ ត្រូវតែមានវត្តមាននៅក្នុងពេលសវនការរឿងក្តីព្រហ្មទណ្ឌ។

ក្នុងករណី ប្រសិនបើជនរងគ្រោះទទួលមរណភាព ឬគ្មានអ្នកតំណាងឲ្យខ្លួនទេសិទ្ធិវន្តនៃជនរងគ្រោះ ឬក្នុងករណីជនរងគ្រោះគ្មានអ្នកតំណាងឲ្យខ្លួនទេ ក្រមនីតិវិធីព្រហ្មទណ្ឌដដែលនេះក៏បានចែងជាកាតព្វកិច្ចចំពោះ

---

[28] មាត្រា ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[29] មាត្រា ១៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[30] មាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

អាជ្ញាធរសាធារណៈ ឬ មន្ត្រីគ្រប់រូបនៅពេលបំពេញការងាររបស់ខ្លួនហើយបានដឹងអំពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ឬ ដល់មន្ត្រីនគរបាលយុត្តិធម៌ ដោយត្រូវបញ្ជូនពត៌មានកំណត់ហេតុ លិខិត និងវត្ថុតាងទាំងអស់ ដែលទាក់ទងនឹងបទល្មើសនោះភ្ជាប់មកជាមួយផង។[31]

**កថាភាគទី៣. ដំណើរការបណ្តឹងអាជ្ញាដោយជនរងគ្រោះ**

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ បុគ្គលគ្រប់រូបដែលប្រកាសថា ខ្លួនជាជនរងគ្រោះនៃបទល្មើស អាចដាក់ពាក្យប្តឹងបាន។ ប៉ុន្តែក្នុងករណីដែលពាក្យបណ្តឹងស្ថិតនៅដោយគ្មានចម្លើយ ឬ ត្រូវតម្កល់ទុកឥតចាត់ការដោយព្រះរាជអាជ្ញាជនរងគ្រោះអាចប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ដូចគ្នានេះដែរ ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។

ចៅក្រមស៊ើបសួរធ្វើការកត់សម្គាល់នូវការដាក់ពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមរយៈដីកា ចៅក្រមស៊ើបសួរបញ្ជូនបណ្តឹងនេះទៅព្រះរាជអាជ្ញា ។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរធ្វើការកត់សំគាល់នូវការដាក់ពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមដីកា។ ក្រោយពីបានឃើញពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅក្រមស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះអាចធ្វើការប្រឆាំងនឹងអញ្ញាតជន ទោះបីជាបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចោទទៅលើឈ្មោះបុគ្គលម្នាក់ ឬ ច្រើននាក់ក៏ដោយ។ ព្រះរាជអាជ្ញាអាចសុំដល់ចៅក្រមស៊ើបសួរកុំឲ្យស៊ើបសួរ ប្រសិនបើបណ្តឹងអាជ្ញាត្រូវបានផុតរលត់ ឬ ប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។ ក្នុងករណីចៅក្រមស៊ើបសួរសម្រេចមិនស៊ើបសួរ ចៅក្រមរូបនេះ ត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងករណីដែលចៅក្រមស៊ើបសួរនៅតែសម្រេចស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងបន្ទាន់ដល់ព្រះរាជអាជ្ញា។[32]

[31] មាត្រា ៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[32] មាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

## ផ្នែកទី២. ការរលត់នៃបណ្តឹងអាជ្ញា

ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌមូលហេតុនៃការរលត់បណ្តឹងអាជ្ញា រួមមាន (១)មរណៈភាពនៃជនល្មើស (២)ការផុតអាជ្ញាយុកាល (៣)ការលើកលែងទោសទូទៅ (៤)និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ (៥)អាជ្ញាអស់ជំនុំ។ កាលណាបណ្តឹងអាជ្ញាត្រូវផុតរលត់ហើយ ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌមិនអាចចាប់ផ្តើមបានទៀតទេ ឬត្រូវតែបញ្ឈប់។ [33]

**មូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញា កាលណាច្បាប់ដោយឡែកបានចែងដោយជាក់លាក់ នោះបណ្តឹងអាជ្ញាក៏អាចផុតរលត់បានដែរៈ**

- ដោយការសម្របសម្រួលជាមួយរដ្ឋ
- ដោយការដកពាក្យបណ្តឹង នៅក្នុងករណីដែលពាក្យបណ្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ ។
- ដោយការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល។[34]

(ឧទាហរណ៍៖ ករណីបទល្មើសព្រៃឈើខ្លះ)

### កថាភាគទី១. មរណភាពនៃជនល្មើស

កាលណាជនល្មើស ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ ដែលកំពុងស្ថិតនៅក្នុងបណ្តឹងអាជ្ញាណាមួយ ហើយជននោះបានទទួលមរណៈភាពជាហេតុនាំឲ្យបណ្តឹងអាជ្ញាដែលកំពុងតែមានលើជននោះ គឺត្រូវរលត់ហើយដំណើរការទាំងឡាយនៃនីតិវិធីនឹងត្រូវបានបិទបញ្ចប់។

### កថាភាគទី២. ការផុតអាជ្ញាយុកាល

អាជ្ញាយុកាល គឺជាពេលវេលាកំណត់មួយដែលមានចែងជាក់លាក់ក្នុងច្បាប់អំពីរយៈពេលដែលអាចធ្វើឬចាប់ផ្តើមបណ្តឹងអាជ្ញាបាន។ ប្រសិនបើសកម្មភាពល្មើសណាមួយត្រូវបានកើតឡើងដែលនាំឲ្យការគិតអំពីអាជ្ញាយុកាលនៃបទល្មើសនោះត្រូវបានចាប់ផ្តើម ហើយដល់រយៈកំណត់នៅតែមិនមានបណ្តឹងអាជ្ញាណាមួយត្រូវបានធ្វើឡើងពាក់ព័ន្ធនឹងសកម្មភាព នោះនាំឲ្យបណ្តឹងអាជ្ញាត្រូវរលត់ដោយមូលហេតុការផុតអាជ្ញាយុកាល។

អាជ្ញាយុកាលមានរយៈពេលខុសៗ ទៅតាមប្រភេទបទល្មើសដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌអាជ្ញាយុកាលនៃបទល្មើសៈ

- បទឧក្រិដ្ឋមានអាជ្ញាយុកាល ១៥(ដប់ប្រាំ)ឆ្នាំ
- បទល្មើសមជ្ឈិមមាន អាជ្ញាយុកាល ៥(ប្រាំ)ឆ្នាំ

[33] មាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[34] មាត្រា ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

- បទល្មើសលហុអាជ្ញាយុកាលមានរយៈពេល ០១(មួយ)ឆ្នាំ។[35]

**ប៉ុន្តែយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឧក្រិដ្ឋកម្ម ដែលគ្មានអាជ្ញាយុកាល មានបទឧក្រិដ្ឋធ្ងន់ធ្ងរមួយចំនួន ច្បាប់មិនមានកំណត់អាជ្ញាយុកាលនោះទេដូចជា៖**

- បទល្មើសប្រល័យពូជសាសន៍
- បទល្មើសប្រឆាំមនុស្សជាតិ
- និងបទល្មើសឧក្រិដ្ឋកម្មសង្គ្រាមជាដើម។[36]

### កថាភាគទី៣. ការលើកលែងទោសជាទូទៅ

ការលើកលែងទោសជាទូទៅ ខុសពីកាលលើកលែងទោសដោយរាជានុសិទ្ធិរបស់ព្រះមហាក្សត្រដែលមានចែងក្នុងច្បាប់ ជាទូទៅធ្វើឡើងជារៀងរាល់ឆ្នាំក្នុងឱកាសនៃព្រះរាជពិធីបុណ្យជាតិធំៗ។ បណ្តឹងអាជ្ញាមួយអាចនឹង ត្រូវរលត់តាមរយៈការលើកលែងទោសជាទូទៅ ដែលការលើកលែងទោសនេះ សំដៅលើការធ្វើច្បាប់ដែលអនុម័តដោយរដ្ឋសភាសម្រាប់លើកលែងទោស ឬ លុបចោលនូវប្រភេទបទល្មើសណាមួយដែលនាំឱ្យបណ្តឹងអាជ្ញាដែល កំពុងដំណើរការក្នុងនីតិវិធីនឹងត្រូវរលត់ ។

### កថាភាគទី៤. និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

បណ្តឹងអាជ្ញាមួយត្រូវបានធ្វើឡើងតាមរយៈ នៃការចោទប្រកាន់របស់អយ្យការក្នុងបទល្មើសណាមួយ ប៉ុន្តែដោយមូលហេតុថាបទល្មើសដែលត្រូវបានចោទប្រកាន់នោះត្រូវបាននិរាករណ៍ដោយមានច្បាប់ព្រហ្មទណ្ឌថ្មីចូលមកលុបចោលបទបញ្ញត្តិណាមួយ ហេតុនេះបណ្តឹងអាជ្ញាដែលធ្វើឡើងដោយឈរលើមូលដ្ឋាននៃបទល្មើសដែលមានចែងក្នុងច្បាប់ចាស់នឹងត្រូវរលត់។

### កថាភាគទី៥. អាជ្ញាអស់ជំនុំ

កាលណាអង្គហេតុនៃបទល្មើសមួយត្រូវបានកើតឡើង ហើយត្រូវបានអយ្យការធ្វើការចោទប្រកាន់ពីបទល្មើសអ្វីមួយ និងមានការជំនុំជម្រះសេចក្តីហូតមានសាលក្រម ឬសាលដីកាស្ថាពរ ហើយអង្គហេតុនោះមិនអាចត្រូវបានលើកយកមកធ្វើការចោទប្រកាន់ជាថ្មីបានឡើយ។

[35] មាត្រា ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[36] មាត្រា ៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

# ជំពូកទី៣
# ការអនុវត្តបណ្ដឹងអាជ្ញា

# ជំពូកទី៣
# ការអនុវត្តបណ្តឹងអាជ្ញា

## ផ្នែកទី១. ជម្រើសនៃការចោទប្រកាន់

ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្តឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក។ ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ មុននឹងសម្រេចព្រះរាជអាជ្ញាបើកការស៊ើបអង្កេតបឋម ឬ បង្គាប់ឲ្យធ្វើការស្រាវជ្រាវបន្ថែម។[37] ក្នុងករណីបទល្មើសធ្ងន់ធ្ងរ ព្រះរាជអាជ្ញារាយការណ៍ជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលត្រូវរាយការណ៍បន្តជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**សម្គាល់**: រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មានអំណាចអាចធ្វើអធិបញ្ញាឲ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសលាដំបូងធ្វើការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែគ្មានអំណាចធ្វើអធិបញ្ញាឲ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការ នូវរឿងក្តីព្រហ្មទណ្ឌណាមួយបានឡើយ។

យោងតាមច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាបានបញ្ញត្តិថា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយឋានានុក្រមនៃអង្គការអយ្យការ ហើយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់។[38]

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬ ទៅព្រះរាជអាជ្ញាអមសាលាដំបូងអំពីបទល្មើសដែលខ្លួនបានដឹង ឬរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរឲ្យអគ្គព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញាអមសាលាដំបូង ធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនអាចធ្វើអធិបញ្ញាដល់អគ្គព្រះរាជអាជ្ញា ឬ ព្រះរាជអាជ្ញាធ្វើការតម្កល់ទុកឥតចាត់ការនូវរឿងក្តីព្រហ្មទណ្ឌណាមួយឡើយ។[39]

តំណាងអយ្យការ ថ្លឹងថ្លែងទៅលើអង្គហេតុ និងធ្វើការចោទប្រកាន់អាស្រ័យទៅតាមប្រភេទនៃបទល្មើស និងស្ថានភាពនៃបទល្មើសជាអាទិ៍ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ការចោទប្រកាន់ជម្រើសនៃការចោទប្រកាន់ខាងបទព្រហ្មទណ្ឌអាចធ្វើតាមៈ

---

[37] មាត្រា ៤០ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[38] មាត្រា ៧៥ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាឆ្នាំ២០១៤

[39] មាត្រា ២៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

- ការបើកធ្វើការស៊ើបសួរ (RI)
- ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ (CD)
- តាមនីតិវិធីបង្គាប់ឲ្យបង្ហាញខ្លួនភ្លាម (CI)។[40]

## កថាភាគទី១. ការបើកធ្វើការស៊ើបសួរ

### ១. ការបើការស៊ើបសួរក្នុងករណីបទឧក្រិដ្ឋ

ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើការស៊ើបសួរ។[41]

យោងតាមក្រមព្រហ្មទណ្ឌបានឲ្យនិយមន័យថា បទឧក្រិដ្ឋ គឺជាបទល្មើសដែលនៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ឬ ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី០៥ឆ្នាំ និង ក្រោម ឬ ស្មើនឹង៣០ឆ្នាំ។[42] ចំពោះទោសដាក់ពន្ធនាគារអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។ មាត្រានេះបញ្ជាក់ឲ្យឃើញថាបទឧក្រិដ្ឋ គឺជាបទល្មើសដែលមានស្ថានភាពធ្ងន់ធ្ងរមានផលប៉ះពាល់ខ្លាំងដល់សង្គម និងមានរយៈពេលវែងក្នុងការដកហូតសិទ្ធិសេរីភាពរបស់បុគ្គល ដូច្នេះតម្រូវឲ្យត្រូវពិនិត្យឲ្យបានល្អិតល្អន់បំផុតមុននឹងធ្វើការសម្រេចអំពីទោស។

តំណាងអយ្យការ ប្តឹងសុំទៅយុត្តាធិការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ គឺជានីតិវិធីមួយដែលតំណាងអយ្យការអាចធ្វើដើម្បីបើកការស៊ើបសួរប្រឆាំងទៅលើបុគ្គលម្នាក់ ឬ ច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ ឬ ប្រឆាំងទៅលើអញ្ញាតជន។

***ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររួមមាន៖***

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គលដែលរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។ ទម្រង់ការនេះត្រូវតែគោរពបើពុំដូចច្នេះទេ ដីកាបញ្ជូនរឿងឲ្យស៊ើបសួរត្រូវមោឃៈភាព។

[40] មាត្រា ៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[41] មាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧

[42] មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

ចៅក្រមស៊ើបសួរ ដែលទទួលបណ្ដឹងអំពីអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការនេះ អាចធ្វើការស៊ើបសួរតែចំពោះអង្គហេតុដែលបញ្ជូនមកឲ្យខ្លួនពិនិត្យតែប៉ុណ្ណោះ។

ក្នុងករណីនេះ មានចំណោទគតិយុត្តមួយបានចោទឡើងថា តើចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរបន្ថែមទៅលើអង្គហេតុថ្មីយ៉ាងដូចម្ដេច?

ស្ថិតនៅក្នុងពេលកំពុងស៊ើបសួរហើយមានលេចចេញអង្គហេតុថ្មី ដែលជាបទល្មើសព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរត្រូវជូនពត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញា អាចប្ដឹងសុំឲ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

ប៉ុន្តែក្នុងករណី តំណាងអយ្យការ មិនព្រមប្ដឹងចោទប្រកាន់ឲ្យស៊ើបសួរបន្ថែមទេ ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈឹម អាចដាក់ពាក្យប្ដឹងជូនចៅក្រមស៊ើបសួរមានសមត្ថកិច្ចដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ គ្រប់បុគ្គលដែលត្រូវបានតំណាងអយ្យការ ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរត្រូវបានផ្លាស់ប្ដូរឋានៈរបស់ខ្លួនទៅជាជនត្រូវចោទ។

ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬ បទមជ្ឈឹម អាចដាក់ពាក្យប្ដឹងជូនចៅក្រមស៊ើបសួរមានសមត្ថកិច្ចដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ពាក្យប្ដឹងអាចដាក់ក្នុងនាមជនរងគ្រោះដោយមេធាវី។[43]

ការបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរធ្វើការកត់សំគាល់នូវការដាក់ពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមដីកា។ ចៅក្រមស៊ើបសួរបញ្ជូនបណ្ដឹងនេះទៅព្រះរាជអាជ្ញា ក្រោយពីបានឃើញពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាត្រូវប្ដឹងទៅចៅក្រមស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ អាចធ្វើប្រឆាំងនឹងអញ្ញាតជន ទោះបីជាបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចោទទៅលើឈ្មោះបុគ្គលម្នាក់ ឬ ច្រើននាក់ក៏ដោយ។ ព្រះរាជអាជ្ញាអាចសុំដល់ចៅក្រមស៊ើបសួរកុំឲ្យស៊ើបសួរ ប្រសិនបើបណ្ដឹងអាជ្ញាត្រូវបានផុតរលត់ ឬ ប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។

ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចមិនស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី។

ក្នុងករណីដែលចៅក្រមស៊ើបសួរនៅតែសម្រេចស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា។[44]

---

[43] មាត្រា ១៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[44] មាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

**២. ការបើកការស៊ើបសួរក្នុងករណីបទមជ្ឈិម**

ក្នុងករណីបទមជ្ឈិម ព្រះរាជអាជ្ញាអាចបើកការស៊ើបសួរ ឬមិនបើកការស៊ើបសួរ។ ករណីបទល្មើសមិនជាក់ស្តែងព្រះរាជអាជ្ញាធ្វើស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។[45]

***ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររួមមានៈ***

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គលដែលរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។ ទម្រង់ការនេះត្រូវតែគោរព បើពុំដូចច្នេះទេ ដីកាបញ្ជូនរឿងឲ្យស៊ើបសួរត្រូវមោឃៈភាព។

**ប៉ុន្តែ ក្នុងករណីព្រះរាជអាជ្ញាមិនបើកការស៊ើបសួរព្រះរាជអាជ្ញាអាចៈ**

- បញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់ នៅមុខតុលាការដំបូង ដូចបានចែងនៅក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។
- បង្គាប់ឲ្យជនជាប់ចោទចូលទៅបង្ហាញខ្លួនភ្លាមនៅមុខតុលាការដំបូង ការបង្ហាញខ្លួនភ្លាម និងនីតិវិធីនៃការបង្ហាញខ្លួនភ្លាម។

**កថាភាគទី២. ការបញ្ជូនទៅជំនុំជម្រះផ្ទាល់**

នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏ជាជម្រើសមួយរបស់តំណាងអយ្យការក្នុងការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌផងដែរ។ នីតិវិធីថ្មីនេះទើបតែបង្កើតឡើងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌថ្មីឆ្នាំ២០០៧នេះ តែប៉ុណ្ណោះ ក្រមនីតិវិធីបានធ្វើការណែនាំឲ្យតំណាងអយ្យការត្រូវតែប្រើនីតិវិធីបញ្ជូនទៅជម្រះផ្ទាល់ចំពោះបទលហុ ឬអាចប្រើនីតិវិធីបញ្ជូនទៅជម្រះផ្ទាល់ចំពោះបទមជ្ឈឹមដែលមានភស្តុតាងគ្រប់គ្រាន់។ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាការបញ្ជាឲ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការ។[46]

***នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់គឺប្រើចំពោះ បទលហុ តែប៉ុណ្ណោះ*** មូលហេតុនៃការប្រើនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ចំពោះបទលហុ ព្រោះបទលហុ គឺជាបទល្មើសដែលអតិបរមានៃការផ្តន្ទាទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬ ស្មើ០៦ថ្ងៃ ឬ ជាប្រភេទបទល្មើសដែលគ្រាន់តែត្រូវផ្តន្ទាទោសពិន័យជាប្រាក់តែ

[45] មាត្រា ៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[46] មាត្រា ៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ប៉ុណ្ណោះ។ ព្រោះតែបទល្មើសលហុត្រូវបានចាត់ទុកថាជាប្រភេទបទល្មើសស្រាលបំផុត ដែលមិនបង្កឲ្យប៉ះពាល់ដល់សន្តិសុខសង្គម ហើយដើម្បីកាត់បន្ថយបន្ទុកចំណាយរបស់រដ្ឋ និងភាគីដើម្បីចំណេញពេលវេលាទើបច្បាប់បានបញ្ញត្តិជាកំហិតថា ក្នុងករណីទទួលបានសំណុំរឿងដែលជាបទលហុ តំណាងអយ្យការត្រូវតែប្រើនីតិវិធីកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។

**ទម្រង់ការនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់៖**

- អត្តសញ្ញាណនៃជនជាប់ចោទ
- សេចក្តីសង្ខេបនៃអង្គហេតុ
- ឈ្មោះបទល្មើស
- អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- ការចង្អុលប្រាប់ពីតុលាការ ព្រមទាំងទីកន្លែង កាលបរិច្ឆេទ និង ម៉ោងពេលនៃសវនាការ។

**រយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជម្រះផ្ទាល់ ឲ្យដល់ជនជាប់ចោទ និងថ្ងៃកំណត់ឲ្យចូលបង្ហាញខ្លួននៅមុខតុលាការត្រូវកំណត់ដូចតទៅ៖**

- ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់តុលាការ
- ២០ (ម្ភៃ) ថ្ងៃ ប្រសិនបើជនជាប់ចោទ រស់នៅក្នុងទីកន្លែងផ្សេងក្នុងដែនដីជាតិ
- ២ (ពីរ) ខែ ប្រសិនបើជនជាប់ចោទ រស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា
- ៣ (បី) ខែ ប្រសិនបើជនជាប់ចោទ រស់នៅក្នុងទីកន្លែងដទៃផ្សេងទៀត។[47]

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ អាចត្រូវប្រគល់ឱ្យជនជាប់ចោទ ដោយផ្ទាល់ដៃដោយព្រះរាជអាជ្ញា។ ក្នុងករណីនេះ ព្រះរាជអាជ្ញាប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដល់ជនជាប់ចោទ។ ព្រះរាជអាជ្ញាចុះនិទ្ទេសស្តីពីកាលបរិច្ឆេទ និងទីកន្លែងប្រគល់ដីកានៅលើដើមដីកា។ ជនជាប់ចោទចុះហត្ថលេខានៅលើដើមដីកានេះ។[48]

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏អាចត្រូវប្រគល់ឲ្យជនជាប់ចោទ ដោយអាជ្ញាសាលាផងដែរ។ អាជ្ញាសាលាត្រូវប្រើប្រាស់គ្រប់មធ្យោបាយដើម្បីប្រគល់ដីកានេះឲ្យជនជាប់ចោទដោយផ្ទាល់ដៃ។[49]

---

[47] មាត្រា៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[48] មាត្រា ៤៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[49] មាត្រា ៤៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ក្នុងករណីជនជាប់ចោទអវត្តមានពីលំនៅឋានរបស់ខ្លួន អាជ្ញាសាលាត្រូវប្រគល់ចុងដីកាឲ្យដល់គ្រប់បុគ្គលទាំងឡាយណាជានីតិជនដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទនោះ។ បុគ្គលដែលទទួលដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ត្រូវសន្យាថានឹងប្រគល់ដីកានោះក្នុងរយៈពេលខ្លីបំផុតដល់ជនជាប់ចោទ។ អាជ្ញាសាលាចុះនិទ្ទេសស្ដីពីអត្តសញ្ញាណនៃបុគ្គលដែលទទួលចុងដីកាកោះចុះនិទ្ទេសស្ដីពីកាលបរិច្ឆេទ និងទីកន្លែងប្រគល់ដីកាហើយមានចុះហត្ថលេខានៅលើដើមដីកានោះ ហើយដើមដីកាត្រូវបញ្ជូនវិលត្រឡប់ទៅតំណាងអយ្យការវិញភ្លាម។[50]

***អាជ្ញាសាលាត្រូវប្រគល់ចុងដីកាកោះឲ្យដល់មេឃុំ ឬ ចៅសង្កាត់ ឬ ជំទប់ ឬ ចៅសង្កាត់រង ក្នុងករណីផ្សេងទៀតដូចជា៖***

- ជនជាប់ចោទមិនព្រមទទួលដីកាកោះហៅបញ្ជូនទៅជម្រះផ្ទាល់
- គ្មានវត្តមានបុគ្គលណាម្នាក់ជានីតិជននៅក្នុងលំនៅឋានរបស់ជនជាប់ចោទទេ
- គ្មានបុគ្គលណាម្នាក់ជានីតិជន ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទព្រមទទួលដីកាកោះនោះទេ។[51]

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ មានអានុភាពជាការប្ដឹងសុំទៅយុត្តាធិកាជំនុំជម្រះឲ្យបើកសវនាការទៅតាមកាលបរិច្ឆេទដែលកំណត់ នៅក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដើម្បីជំនុំជម្រះលើអង្គសេចក្ដីចំពោះបទលហុ ឬ បទមជ្ឈឹមដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌកថាខណ្ឌទី២ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកានេះត្រូវចង្អុលប្រាប់តុលាការ ព្រមទាំងទីកន្លែងកាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការ ដីកានេះត្រូវបញ្ជាក់ថា ជនជាប់ចោទអាចពឹងមេធាវីឲ្យអមខ្លួនបាន។[52] មានន័យថា ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការត្រូវកំណត់ឡើងដោយតំណាងអយ្យការ នៅក្នុងដីកាកោះហៅបញ្ជូនទៅជម្រះផ្ទាល់តែម្ដង ហើយជនជាប់ចោទអាចពឹងមេធាវីឲ្យអមខ្លួនបាន។ ដោយសារផ្អែកលើមូលហេតុដូច្នេះហើយ ទើបយើងយល់ថាអានុភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះបានបំពានទៅលើសិទ្ធិអំណាចរបស់ប្រធានសាលាដំបូង ដែលពីដំបូងជាបុគ្គលតែម្នាក់គត់ដែលមានអំណាចកំណត់អំពីកាលបរិច្ឆេទនៃសវនាការ។

[50] មាត្រា ៤៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[51] មាត្រា ៤៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[52] មាត្រា ៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

**កថាភាគទី៣. នីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម**

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជអាជ្ញា អាចប្រើនីតិវិធីបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមបាន នៅមុខតុលាការដំបូងប្រសិនបើមានលក្ខខណ្ឌដូចតទៅៈ

- បទល្មើសជាបទល្មើសជាក់ស្តែង តាមអត្ថន័យ(និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) និង(ការចាត់ទុកបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង)
- បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ០១ឆ្នាំ និងយ៉ាងច្រើន ០៥ (ប្រាំ) ឆ្នាំ។
- ជនជាប់ចោទជាអនីតិជន
- រឿងក្តីមានលក្ខខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះផ្ទាល់។

កាលណាតំណាងអយ្យការសម្រេចប្រើនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម សេចក្តីសម្រេចនោះមានអានុភាពបញ្ជាទៅដល់កម្លាំងសាធារណៈ ដែលមានសមត្ថកិច្ចឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញនៅមុខតុលាការជាន់ដំបូងភ្លាម បន្ទាប់ពីផ្ទៀងផ្ទាត់អត្តសញ្ញាណជនជាប់ចោទរួចរាល់ហើយតុលាការដែលទទួលបន្ទុកជំនុំជម្រះត្រូវបើកសវនាការនៅថ្ងៃនោះតែម្តង។[53]

នីតិវិធីបង្ហាញខ្លួនភ្លាមនេះ គឺជានីតិវិធីថ្មីដែលស្តែងឲ្យឃើញអំពីការបង្កើនល្បឿនចំពោះចំណាត់ការរឿងក្តីរបស់ស្ថាប័នតុលាការដែលជំរុញឲ្យការស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋបានឆាប់រហ័ស។ ប៉ុន្តែពេលខ្លះមានការយល់ឃើញថា ការធ្វើឲ្យឆាប់រហ័សពេកក៏បានប៉ះពាល់ដល់សិទ្ធិរបស់ភាគីនៃរឿងក្តីផងដែរ។ ហេតុដូច្នេះហើយទើបច្បាប់បានបញ្ញត្តិអំពីលក្ខខណ្ឌមួយចំនួនដែលតម្រូវឲ្យអ្នកអនុវត្តត្រូវតែគោរពផងដែរ។ នៅពេលមន្ត្រីនគរបាលយុត្តិធម៌បានបញ្ជូនសំណុំរឿង និងបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួនមកឲ្យតំណាងអយ្យការ ព្រះរាជអាជ្ញាអាចបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូងបាន បន្ទាប់ពីបានពិនិត្យឃើញថាសំណុំរឿងក្តីព្រហ្មទណ្ឌនោះបានបំពេញគ្រប់លក្ខខណ្ឌដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។

**កាលណាសម្រេចថាត្រូវប្រើនីតិវិធីបង្គាប់ឲ្យបង្ហាញខ្លួនភ្លាមព្រះរាជអាជ្ញាៈ**

- ត្រូវពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឲ្យខ្លួន
- ឲ្យដំណឹងដល់ជននោះអំពីរឿងរ៉ាវដែលចោទប្រកាន់ និងឈ្មោះបទល្មើស
- ទទួលចម្លើយរបស់បុគ្គលនោះ បើសិនសាមីខ្លួនចង់និយាយ
- ធ្វើកំណត់ហេតុស្តីអំពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។

[53] មាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ព្រះរាជអាជ្ញាប្រាប់ជនជាប់ចោទថា ខ្លួនមានសិទ្ធិពឹងមេធាវីខ្លួនបាន។ តាមការជ្រើសរើសរបស់ខ្លួន ឬ តាមការចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

មេធាវីជ្រើសរើស ឬដាក់តាំងត្រូវបានទទួលដំណឹងភ្លាម។ មេធាវីអាចពិនិត្យសំណុំរឿង និងទាក់ទង ជាមួយជនជាប់ចោទបាន។

និទ្ទេសនៃទម្រង់ការទាំងនេះ ត្រូវចុះនៅក្នុងកំណត់ហេតុ បើពុំដូច្នោះទេនីតិវិធីត្រូវជាមោឃៈ។

តុលាការដំបូង ត្រូវបានទទួលបណ្តឹងតាមកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។

ជនជាប់ចោទត្រូវបង្ខាំងទុកដោយមានកងកម្លាំងការពារ រហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួននៅ ចំពោះមុខតុលាការដែលត្រូវបើកសវនាការនៅក្នុងថ្ងៃនោះតែម្តង ។

នៅពេលបង្ហាញខ្លួននេះ តុលាការក្រោយពីបានផ្ទៀងផ្ទាត់មើលអត្តសញ្ញាណរបស់ជនជាប់ចោទ និងធ្វើ របាយការណ៍សង្ខេបរឿងដែលបានចោទប្រកាន់ ត្រូវប្រាប់ដល់ជនជាប់ចោទថា សាមីខ្លួនអាចមានរយៈពេល ដើម្បីរៀបចំការពារខ្លួន។

ប្រសិនបើជនជាប់ចោទសុំរយៈពេល ឬប្រសិនបើតុលាការយល់ឃើញថា រឿងក្តីនោះមិនទាន់អាចជំនុំ ជម្រះភ្លាមៗ បានទេនោះ សំណុំរឿងត្រូវលើកទៅពេលសវនការក្រោយ។

តុលាការអាចបង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទ ជាបណ្តោះអាសន្ន ដោយសាលក្រមដែលមានបញ្ជាក់ពី សំអាងហេតុ។ នៅក្នុងសាលក្រមនោះតុលាការត្រូវយោងតាមលក្ខខណ្ឌនៃមាត្រា ២០៥ មូលហេតុនៃការឃុំខ្លួន បណ្តោះអាសន្ន។

ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្តោះអាសន្ននេះជាការចាំបាច់៖

-ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី ។

-ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជន ត្រូវចោទ និងអ្នកសមគំនិត ។

-ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសម្ភារៈ

-ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី

-ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ

-ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។

សាលក្រមលើអង្គសេចក្តីត្រូវតែប្រកាសក្នុងរយៈពេលដែលមិនអាចលើសពី ២ (ពីរ) សប្តាហ៍ គិតពីថ្ងៃចូលទៅបង្ហាញខ្លួននៅមុខតុលាការ។ ការឃុំខ្លួនបណ្តោះអាសន្នត្រូវតែបញ្ឈប់ ដោយពេញច្បាប់ក្រោយពីផុតរយៈពេល ២ (ពីរ) សប្តាហ៍។[54]

ប្រសិនបើតុលាការដែលបានទទួលបណ្តឹងតាមតាវិធីបង្គាប់ឲ្យបង្ហាញខ្លួនភ្លាម យល់ឃើញថាលក្ខខណ្ឌនៃក្រមនេះមិនបានបំពេញ ឬ មានភាពសាំញ៉ាំនៃសំណុំរឿងតម្រូវជាចាំបាច់ឲ្យធ្វើការស្រាវជ្រាវឲ្យបានជ្រាលជ្រៅបន្ថែម តុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរ។ ជនជាប់ចោទត្រូវតែនាំទៅ បង្ហាញខ្លួននៅថ្ងៃនោះតែម្តងនៅចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នោះទេ ជនជាប់ចោទត្រូវតែដោះលែងឲ្យមានសេរីភាពវិញដោយឯកឯង។[55]

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ក្នុងករណីបទលហុប្រសិនបើរឿងនោះជាបទលហុ ព្រះរាជអាជ្ញាត្រូវកោះជនជាប់ចោទឲ្យចូលខ្លួនទៅមុខតុលាការជំនុំជម្រះដោយផ្ទាល់ ដូចបានចែងនៅក្នុងច្បាប់ (ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់)នៃក្រមនេះ។[56]

តំណាងអយ្យការ ធ្វើបណ្តឹងសុំឲ្យជំនុំជម្រះទៅយុត្តាធិកាជំនុំជម្រះនៃតុលាការដំបូង តាមរយៈកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។ ក្នុងករណីសម្រេចថា ត្រូវប្រើនីតិវិធីបង្ហាញខ្លួនភ្លាម តំណាងអយ្យការកំណត់កាលបរិច្ឆេទនៃសវនាការ នៅក្នុងកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមនោះតែម្តង។ បន្ទាប់មកទៀតតំណាងអយ្យការត្រូវកោះហៅជនរងគ្រោះ សាក្សី អ្នកបកប្រែ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីឲ្យចូលរួមសវនាការផងដែរ។

នីតិវិធីបង្ហាញខ្លួនភ្លាមនេះ បានផ្លាស់ប្តូរឋានៈបុគ្គលដែលបញ្ជូនមកនោះទៅជាជនជាប់ចោទ។ ជនជាប់ចោទត្រូវបង្ខាំងទុកដោយមានកងកម្លាំងការពារ រហូតដល់សាមីខ្លួនចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការដំបូង។ តុលាការដែលទទួលបានបណ្តឹងតាមនីតិវិធីបង្ហាញខ្លួនភ្លាមនេះត្រូវបើកសវនាការជំនុំជម្រះលើអង្គសេចក្តីនៅក្នុងថ្ងៃនោះតែម្តង។ លើកលែងតែជនជាប់ចោទសុំពេល ឬ ប្រសិនបើតុលាការយល់ឃើញថារឿងក្តីមិនទាន់អាចជំនុំជម្រះភ្លាមៗបាន។

[54] មាត្រា ៣០៤ កថាខណ្ឌ ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[55] មាត្រា ៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[56] មាត្រា ៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

# ផ្នែកទី២. ការតម្កល់រឿងទុកឥតចាត់ការ

ដំណើររឿងក្តីព្រហ្មទណ្ឌនៅសាលាក្តីជាន់ទាប ត្រូវបានបែងចែកជា ៤ ដំណាក់កាលគឺ ដំណាក់កាលស៊ើបអង្កេត ដំណាក់កាលចោទប្រកាន់ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ។ ហើយដំណាក់កាលចោទប្រកាន់ គឺជាដំណាក់កាលមួយដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ស្ថាប័នអយ្យការ (ជាម្ចាស់បណ្តឹងអាជ្ញា) ដែលអាចសម្រេចចោទប្រកាន់ និងបញ្ជូនទៅសុំណុំរឿងទៅយុត្តាស៊ើបសួរ និងយុត្តាជំនុំជម្រះ។

យោងតាមជម្រើសនៃការចោទប្រកាន់ ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យបណ្តឹង និងពាក្យបរិហារដែលខ្លួនទទួលបានដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក។ ដោយផ្អែកតាមអត្ថន័យនេះហៅថា គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ទន្ទឹមគ្នានេះផងដែរមានន័យថា ព្រះរាជអាជ្ញាអាចធ្វើការសម្រេចចិត្តចោទប្រកាន់ផង និងតម្កល់រឿងទុកឥតចាត់ការផង ចំពោះបទល្មើសព្រហ្មទណ្ឌ។

យោងតាមការតម្កល់រឿងទុកឥតចាត់ការ កាលណាពាក្យបណ្តឹងណាមួយត្រូវបានតម្កល់ទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវជូនដំណឹងទៅដល់អ្នកប្តឹងអំពីសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល ០២ (ពីរ)ខែ គិតចាប់ពីថ្ងៃចុះពាក្យបណ្តឹងក្នុងបញ្ជីដែលមានចែងក្នុង (បញ្ជីនៃពាក្យបណ្តឹង) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ការតម្កល់រឿងទុកឥតចាត់ការ ត្រូវតែមានសំអាងច្បាប់ និងសំអាងហេតុ។ ការតម្កល់រឿងទុកឥតចាត់ការនេះគ្មានអាជ្ញាអស់ជំនុំទេ។ ព្រះរាជអាជ្ញា អាចសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញ ក្នុងខណៈដែលបណ្តឹងអាជ្ញាមិនទាន់ផុតរលត់នៅឡើយ។[57]

គោលបំណងនៃការសម្រេចតម្កល់រឿងទុកឥតចាត់ការ ដើម្បីជៀសវាងការប្តឹងផ្តល់ដោយគ្មានមូលដ្ឋានច្បាប់។ ព្រះរាជអាជ្ញាសាលាដំបូងរាជធានី និងសាលាដំបូងខេត្ត-ក្រុងទាំងអស់អាចតម្កល់រឿងឥតចាត់ការទៅតាមគោលការណ៍ និងលក្ខខណ្ឌដែលបានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ បន្ទាប់ពីព្រះរាជអាជ្ញា បានទទួលពាក្យបណ្តឹងអាជ្ញាពីរូបវន្តបុគ្គលតាមរយៈការធ្វើបណ្តឹងបរិហារ ឬទទួលបានពីមន្ត្រីនគរបាលយុត្តិធម៌។

## កថាភាគទី១. មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ

### ១. ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលមិនមែនជាបទល្មើស

អំពើខ្លះរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កចលាចលដល់សង្គម ជាបទល្មើស ។ បទល្មើសត្រូវបានចាត់ថ្នាក់ជាបទឧក្រិដ្ឋ បទមជ្ឈឹម និង បទលហុ ទៅតាមទម្ងន់នៃបទល្មើសនោះ។[58]

ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្តចេតនាប្រព្រឹត្តបទល្មើស)។[59]

---

[57] មាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[58] មាត្រា ២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

**អំពើមួយដែលត្រូវចាត់ទុកថាជាបទល្មើស លុះត្រាតែមានធាតុផ្សំ ៣ គឺ៖**

**១-ធាតុនីត្យានុកូល** យោងក្រមព្រហ្មទណ្ឌបានចែងថា មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះ មានចែងនៅមានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន ។ មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន។[60]

មានន័យថា ធាតុនីត្យានុកូលជាធាតុផ្សំនៃបទល្មើសមួយ ដែលច្បាប់បានចែងជាធរមាន ដែលស្របទៅតាមគោលការណ៍នីត្យានុគោលភាព។ យោងតាមអត្ថន័យនេះមានន័យថា គ្មានបទល្មើសទេ គ្មានទោសទេ បើគ្មានច្បាប់ចែង។

**២-សន្យានុម័ត ឬធាតុសម្ភារ** សំដៅទៅលើ អំពើវិជ្ជមាន ឬ អំពើអវិជ្ជមានដែលប្រព្រឹត្ត ដោយបុគ្គលណាម្នាក់ហើយស្តែងចេញជាសម្ភារៈមកខាងក្រៅទោះដោយអំពើសកម្មក្តី ឬ អំពើអកម្មក្តី ដែលអំពើនោះបណ្តាលឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬ សិទ្ធិសេរីភាពបូរណភាពផ្លូវកាយ បូរណភាពផ្លូវចិត្ត។ ចំពោះអំពើសកម្ម ដែលជាសកម្មភាពជាបទល្មើសដែលមានធាតុផ្សំសត្យានុម័តជាសកម្មភាពវិជ្ជមាន ឬជាអំពើវិជ្ជមាន។ ដែលមានន័យថា ចារីបានប្រព្រឹត្តបទល្មើសយ៉ាងស្វិតស្វាញដើម្បីសម្រេចនូវគោលបំណងរបស់ខ្លួន។

**២-ធាតុអត្តនោម័ត ឬស្ថានភាពផ្លូវចិត្ត** សំដៅទៅលើ កិរិយាផ្លូវចិត្តរបស់ជនល្មើស ឬឆន្ទៈរបស់ចារីក្នុងការប្រព្រឹត្តបទល្មើសដែលក្នុងនោះអាចជាកំហុសចេតនា ឬកំហុសអចេតនា។ កំហុសចេតនា សំដៅទៅលើចេតនាក្នុងការប្រព្រឹត្តបទល្មើស មានឆន្ទៈក្នុងការប្រព្រឹត្តបទល្មើស។ ដែលមានន័យថា ចារីបានដឹងថា អំពើរបស់ខ្លួន ជាអំពើដែលច្បាប់ហាមឃាត់ ប៉ុន្តែចារីនៅតែព្យាយាមប្រព្រឹត្ត ដែលនេះស្របតាមនៃក្រមព្រហ្មទណ្ឌបានចែងថា ពុំមានបទល្មើសទេ ប្រសិនបើគ្មាន ចេតនាប្រព្រឹត្ត។ ចេតនាក្នុងការប្រព្រឹត្តបទល្មើស ឬត្រូវបានគេហៅម្យ៉ាងទៀតថា ជាចេតនាទុច្ចរិត មានច្រើនប្រភេទដូចជា ចេតនាទុច្ចរិតទូទៅ ចេតនាទុច្ចរិតពិសេស ចេតនាទុច្ចរិតធ្ងន់ធ្ងរ ចេតនាទុច្ចរិតច្បាស់លាស់ និងមិនច្បាស់លាស់ និងចេតនាទុច្ចរិតចំពោះ និងមិនចំពោះ។ មាន័យថា ធាតុអត្តនោម័ត ឬស្ថានភាពផ្លូវចិត្ត គឺជាចិត្តគំនិតខាងក្នុងរបស់ជនល្មើសដែលស្តែងចេញមកខាងក្រៅតាមរយៈធាតុសត្យានុម័ត។

ដូចនេះ ប្រសិនបើករណីមានកង្វះនូវធាតុផ្សំណាមួយ តំណាងអយ្យការនឹងសម្រេចថាតម្កល់រឿងទុកឥតចាត់ការបាន។

[59] មាត្រា ៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[60] មាត្រា ៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

## ២. ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើជាបទល្មើស

ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើជាបទល្មើស កាលណាការចោទប្រកាន់មិនផ្តល់ប្រយោជន៍ ដោយយោង គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ការចោទប្រកាន់របស់អយ្យការទៅលើស្ថានភាព ដែលពាក់ព័ន្ធទៅលើកត្តាដូចជា៖ ចារី សហចារី ជនសង្ស័យ ជនល្មើស ជនរងគ្រោះ ជាអាទិ៍។ មានន័យថា ការចោទប្រកាន់របស់អយ្យការ មិនមានផ្តល់ប្រយោជន៍ដល់សង្គម ឬ ផ្ទុយពីគោលបំណងនៃបណ្តឹងអាជ្ញា ដូចនេះ អយ្យការអាចតម្កល់រឿងទុកឥតចាត់ការបាន។

### ២.១. មូលហេតុគតិយុត្តដែលនាំឲ្យតម្កល់រឿងទុកឥតចាត់ការ

ការផុតរលត់នៃបណ្តឹងអាជ្ញានៃក្រមនីតិវិធីព្រហ្មទណ្ឌ៖

- មរណភាពនៃជនល្មើស
- ការផុតអាជ្ញាយុកាល
- ការលើកលែងទោសជាទូទៅ
- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ
- អាជ្ញាអស់ជំនុំ។

មូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញា កាលណាច្បាប់ដោយឡែក បានចែងដោយជាក់លាក់ នោះបណ្តឹងអាជ្ញាក៏អាចផុតរលត់បានដែរក្នុងករណីដូចខាងក្រោម៖

- ដោយការសម្របសម្រួលជាមួយរដ្ឋ
- ដោយការដកពាក្យប្តឹង នៅក្នុងករណីដែលពាក្យប្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃ
- ការចោទប្រកាន់ជាបទព្រហ្មទណ្ឌ
- ដោយការបង់ប្រាក់ពិន័យសរុបឬប្រាក់ពិន័យសម្របសម្រួល ។[61]

ប៉ុន្តែ ឧក្រិដ្ឋកម្មដែលគ្មានអាជ្ញាយុកាលកំណត់រួមមាន៖ បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាមមិនអាចផុតអាជ្ញាយុកាលបានទេ។

### ២.២ ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ

ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ក៏ជាមូលហេតុដែលនាំឲ្យតម្កល់រឿងទុកឥតចាត់ការផងដែរ មូលហេតុទាំងនោះរួមមាន៖

[61] មាត្រា៧ និង ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

- **ក្រមព្រហ្មទណ្ឌ ការមិនទទួលខុសត្រូវដោយសារមូលហេតុវិបល្លាសស្មារតី**

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឲ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។

កាលបើជនណាម្នាក់ព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួនជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។ ប៉ុន្តែ តុលាការត្រូវគិតគូរអំពីបញ្ហានេះកាលណាតុលាការកំណត់ទោស។

កាលបើជនណាម្នាក់បព្រឹត្តបទល្មើសនៅពេលដែលជននោះ កើតវិបល្លាសស្មារតីដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬ សារជាតិដែលច្បាប់បានហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។[62]

- **ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ**

បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្ត ឬអនុញ្ញាតតាមច្បាប់ បុគ្គលនោះ មិនប្រព្រឹត្តបទល្មើសទេ។

បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់។

ប៉ុន្តែ ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬ បទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេទោះបីជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ :

១-ជនល្មើសនោះបានប្រព្រឹត្តអំពើដែលបញ្ញត អនុញ្ញាត ឬមិនហាមឃាត់ដោយច្បាប់ជាធរមាន

២-បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរ ស្របច្បាប់។[63]

- **ការការពារស្របច្បាប់**

បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ៖

- បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួនការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ
- បទល្មើស និងការឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និងគ្មានវិសមាមាត្ររវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន។[64]

[62] មាត្រា៣១ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[63] មាត្រា ៣២ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

- **សច្ចធារណ៍នៃការការពារស្របច្បាប់**

ត្រូវសន្មតថាជាការការពារស្របច្បាប់ នៅក្នុងករណីដូចតទៅ៖

១-បទល្មើសត្រូវបានប្រព្រឹត្តដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ ។

២-បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬ ការប្លន់ដែលអនុវត្តដោយហិង្សា។ សច្ចធារណ៍នៃការការពារស្របច្បាប់ពុំមានលក្ខណៈដាច់ខាតទេ។[65]

- **ស្ថានភាពចាំបាច់**

បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវ ព្រហ្មទណ្ឌទេ ។ ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ ៖

- បទល្មើសត្រូវបានចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួនការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន និង
- គ្មានវិសមាមាត្ររវាងមធ្យោបាយការពារនិងទម្ងន់នៃគ្រោះថ្នាក់។[66]

- **អានុភាពនៃកម្លាំង ឬ ការបង្ខំ**

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំ ដែលបុគ្គលនេះមិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។

កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែ ប៉ុណ្ណោះ។ កម្លាំង និងការបង្ខំនេះត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិន អាចជៀសវាងបាន។[67]

- **ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ**

បុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ មិនត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌណាមួយឡើយ។[68]

**កថាភាគទី២. នីតិវិធីការតម្កល់រឿងទុកឥតចាត់ការ**

ព្រះរាជអាជ្ញាត្រូវឲ្យដំណឹងដល់អ្នកប្តឹង ក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល ២ (ពីរ)ខែ គិតចាប់ពីថ្ងៃចុះពាក្យបណ្តឹងដែលមានខ្លឹមសារដូចខាងក្រោម៖នីតិវិធីត្រូវបានអនុវត្តដូចតទៅ៖

[64] មាត្រា ៣៣ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[65] មាត្រា ៣៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[66] មាត្រា ៣៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[67] មាត្រា ៣៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

[68] មាត្រា ៣៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩

- អត្តសញ្ញាណរបស់អ្នកប្តឹង
- កាលបរិច្ឆេទដែលអយ្យការ(ព្រះរាជអាជ្ញា)បានទទួលពាក្យបណ្តឹង
- ប្រភពនៃពាក្យបណ្តឹងផ្ទាល់មាត់ ឬមកពីនគរបាលយុត្តិធម៌
- ប្រភេទនៃរឿងហេតុដែលអ្នកប្តឹងបានរាយការណ៍។

ប្រសិនបើអ្នកប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ សាមីខ្លួនអាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន ។

## កថាភាគទី៣. ការធ្វើបណ្តឹងតវ៉ាចំពោះការតម្កល់រឿងទុកឥតចាត់ការរបស់អយ្យការ

### ១. ការប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

ការតម្កល់នេះត្រូវធ្វើនៅក្នុងរយៈពេល ២ (ពីរ)ខែ គិតពីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ ការតវ៉ានេះត្រូវធ្វើតាមបណ្តឹងសាមញ្ញនៅអង្គការអយ្យការដែលពាក់ព័ន្ធ បន្ទាប់មកសំណុំរឿងត្រូវបានបញ្ជូនភ្លាមទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដោយតំណាងអយ្យការអមសាលាដំបូង ។

ប្រសិនបើយល់ឃើញថា ការតវ៉ានេះមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចេញអធិបញ្ញាដល់ព្រះរាជអាជ្ញាអមសាលាដំបូងឲ្យធ្វើការចោទប្រកាន់។ អគ្គព្រះរាជអាជ្ញា ធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ។ នៅក្នុងករណីផ្ទុយពីនេះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូង ទុកជាបានការ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវឲ្យដំណឹងអំពីសេចក្តីសម្រេចនេះដល់អ្នកប្តឹងតវ៉ា ។

### ២. ឋានានុក្រមនៃអង្គការអយ្យការ

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬ ព្រះរាជអាជ្ញាអមសាលាដំបូង អំពីបទល្មើសដែលខ្លួនបានដឹង អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរដែលត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងឲ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ រដ្ឋមន្ត្រីមិនអាចធ្វើអធិបបញ្ញាដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាឱ្យធ្វើការតម្កល់រឿងទុកឥតចាត់ការនូវរឿងក្តីព្រហ្មទណ្ឌណាមួយឡើយ។

### ៣. ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ

បណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈឹម អាចដាក់ពាក្យបណ្តឹងជូនទៅចៅក្រមស៊ើបសួរមានសមត្ថកិច្ច ដោយការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ពាក្យបណ្តឹងអាចដាក់ក្នុងនាមជនរងគ្រោះដោយមេធាវី។

ការដាក់ពាក្យបណ្តឹងអាជ្ញាដោយជនរងគ្រោះ ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬ បទមជ្ឈឹម អាចដាក់ពាក្យបណ្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ។ ពាក្យបណ្តឹងដោយមានតាំង

ខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរ អំពីបណ្តឹងអាជ្ញានៅក្នុងលក្ខខណ្ឌដែលបញ្ញត្តិបានចែង។[69]

ចៅក្រមស៊ើបសួរធ្វើការកត់សំគាល់នូវការដាក់ពាក្យប្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមដីកា។ ក្រោយពីបានឃើញពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅក្រមស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះអាចធ្វើប្រឆាំងនឹងអញ្ញាតជន ទោះបីជាបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចោទទៅលើឈ្មោះបុគ្គលម្នាក់ ឬ ច្រើននាក់ក៏ដោយ។ ព្រះរាជអាជ្ញាអាចសុំដល់ចៅក្រមស៊ើបសួរកុំឲ្យស៊ើបសួរ ប្រសិនបើបណ្តឹងអាជ្ញាត្រូវបានផុតរលត់ ឬ ប្រសិនបើអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ។ ក្នុងករណីចៅក្រមស៊ើបសួរសម្រេចមិនស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងករណីដែលចៅក្រមស៊ើបសួរនៅតែសម្រេចស៊ើបសួរ ចៅក្រមរូបនេះត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយត្រូវជូនដំណឹងបន្ទាន់ដល់ព្រះរាជអាជ្ញា។[70]។

**ការបង់ប្រាក់តម្កល់ទុក** ដោយផ្អែកទៅលើធនធាននៃដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងដែលអាចមើលឃើញជាមុន ចៅក្រមស៊ើបសួរកំណត់តាមដីកាសម្រេចនូវចំនួនទឹកប្រាក់ដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ ព្រមទាំងរយៈពេលដែលត្រូវបង់ប្រាក់នេះផង។[71]

ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីពុំមានលទ្ធភាពអាចបង់ប្រាក់តម្កល់ទុកបានទេ ចៅក្រមស៊ើបសួរអាចលើកលែងមិនឲ្យបង់ប្រាក់នេះបាន។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។

ក្នុងករណីដែលមានការបង់ប្រាក់តម្កល់ទុក ដើមបណ្តឹងរដ្ឋប្បវេណីទទួលបង្កាន់ដៃដែលមានចុះហត្ថលេខាដោយប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី។

ប្រសិនបើប្រាក់តម្កល់ទុកមិនត្រូវបានបង់នៅក្នុងរយៈពេលដែលកំណត់ដោយចៅក្រមស៊ើបសួរទេ ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវប្រកាសថាមិនអាចទទួលបានដោយចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរសម្រេចតាមដីកាដែលត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។

ប្រាក់តម្កល់ទុកត្រូវបង្វិលទៅសាមីខ្លួននៅពេលបញ្ចប់ទីពីរ លើកលែងតែត្រូវអនុវត្តបទប្បញ្ញត្តិនៃបណ្តឹងដោយបំពាន ឬ បណ្តឹងដោយអូសបន្លាយពេលវេលានៃក្រមនេះ ។

---

[69] មាត្រា ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[70] មាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

[71] មាត្រា ១៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

ប្រាក់តម្កល់ទុកត្រូវតម្កល់ទុកនៅក្នុងគណនីពិសេសដែលបើកនៅក្នុងធនាគារ ឬ រក្សាទុកនៅក្នុងទីកន្លែងដែលមានការធានាសន្តិសុខយ៉ាងរឹងមាំទីកន្លែងនេះ ត្រូវបានជ្រើសរើសតាមការព្រមព្រៀងគ្នារបស់ប្រធានតុលាការ និងព្រះរាជអាជ្ញា។

**បណ្តឹងដោយបំពានឬបណ្តឹងដោយអូសបន្លាយពេលវេលា** ប្រសិនបើការស៊ើបសួរដែលបានបើកបន្ទាប់ពីមានពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបិទតាមដីកាលើកលែងចោទប្រកាន់ ហើយប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថា នីតិវិធីធ្វើឡើងដោយរំលោភ ឬដោយអូសបន្លាយពេលវេលា នោះចៅក្រមស៊ើបសួរ អាចសម្រេចតាមដីកាសម្រេចឱ្យដើមបណ្តឹងបង់ប្រាក់ពិន័យរដ្ឋប្បវេណី ចំនួនប្រាក់ពិន័យមិនអាច លើសចំនួនទឹកប្រាក់តម្កល់ទុកឡើយ ។ ដីកាសម្រេចឱ្យ បង់ប្រាក់ពិន័យនេះ ត្រូវឲ្យដំណឹងដល់សាមីខ្លួនជាបន្ទាន់។[72]

**កថាភាគទី៤. អនុភាពនៃការតម្កល់រឿងទុកឥតចាត់ការ**

**១. ការតម្កល់រឿងទុកឥតចាត់ការគ្មានអាជ្ញាអស់ជំនុំទេ**

ដោយអនុវត្តតាមគោលការណ៍អាជ្ញាអស់ជំនុំ ជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ។ ប៉ុន្តែការតម្កល់រឿងទុកឥតចាត់ការគ្មានអាជ្ញាអស់ជំនុំទេ។

ដូចនេះ ការតម្កល់រឿងទុកឥតចាត់ការមិនអាចបង្កើតអាជ្ញាអស់ជំនុំទេ មានន័យថា តំណាងអយ្យការអាចធ្វើការចោទប្រកាន់ឡើងវិញនៅពេលក្រោយបាន ទោះបីបានធ្វើការតម្កល់រឿងទុកឥតចាត់ការ រួចហើយក៏ដោយ។

**២. ការសើរើកែប្រែសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញាអាចសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញ ក្នុងខណៈដែលបណ្តឹងអាជ្ញាមិនទាន់ត្រូវផុតរលត់ឡើយ។ មានន័យថា នៅពេលដែលលេចចេញអង្គហេតុថ្មី ឬ ភស្តុតាងថ្មីណាមួយដែលនាំឲ្យតំណាងអយ្យការអាចកំណត់បានសញ្ញាណថ្មី និងមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការចោទប្រកាន់ឡើងវិញបាន ប៉ុន្តែស្ថិតក្នុងលក្ខខណ្ឌដែលបណ្តឹងអាជ្ញាមិនទាន់ផុតរលត់ប៉ុណ្ណោះ។

អាជ្ញាយុកាលមានរយៈពេលខុសៗ ទៅតាមប្រភេទបទល្មើសដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ អាជ្ញាយុកាលនៃបទល្មើស (១)បទឧក្រិដ្ឋមានអាជ្ញាយុកាល ១៥(ដប់ប្រាំ)ឆ្នាំ (២)បទល្មើសមជ្ឈិមមាន អាជ្ញាយុកាល ៥(ប្រាំ)ឆ្នាំ បទល្មើសលហុអាជ្ញាយុកាលមានរយៈពេល ០១(មួយ)ឆ្នាំ។[73]

---

[72] មាត្រា ១៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧

